ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំ ទី ៤ លេខ ៧ - ៨ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១២-០២-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៤ តែងតាំង ឯកឧត្តម សម សុត្ថា ជានាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា	៤០៥
១៦-០២-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៥ តែងតាំង ឯកឧត្តម សើ គុសល ជាបេសកជនពិសេសរបស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី ១	៤០៦
១៦-០២-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៦ តែងតាំង ឯកឧត្តម ហួត ម៉ុងលី ជាឧត្តមសេនីយ៍ទោ នៃកងយោធពលខេមរភូមិន្ទ	៤០៧
២៧-០២-១៩៩៦	ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៧ អនុញ្ញាតឱ្យឯកឧត្តម ខៀវ វិញា លាលែងចេញពីមុខតំណែងជាអនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	៤០៨

II - ទីស្ដីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

២១-០២-១៩៩៦	អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មការ អន្តរក្រសួងពិនិត្យវាយតម្លៃជ្រើសរើសលើគំរោងការបូមដីបាត ទន្លេ ស្ទឹង ព្រែក និង បឹង	៤០៩
២៧-០២-១៩៩៦	អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	៤១២
២៧-០២-១៩៩៦	អនុក្រឹត្យលេខ ២៧ អនក្រ.តត ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ	៤១៣

២៧-០២-១៩៩៦ អនុក្រឹត្យលេខ ២៨ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤១៥

២៧-០២-១៩៩៦ អនុក្រឹត្យលេខ ២៩ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤១៦

២៧-០២-១៩៩៦ អនុក្រឹត្យលេខ៣០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤១៧

២ - សារាចរ

២៣-០២-១៩៩៦ សារាចរ លេខ ០៣ ស.រ ស្តីពីការធ្វើផ្លាកលេខយានយន្តគ្រប់ប្រភេទ ៤១៩

២៧-០២-១៩៩៦ សារាចរណែនាំលេខ ០១ សរណន ស្តីពីការរៀបចំទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ ១៩៩៦ ខួបលើកទី ៨៦ នៅគ្រប់ក្រសួងស្ថាប័ន និង ខេត្ត ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ៤២២

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

២៤-០២-១៩៩៦ ប្រកាសលេខ ០៤៨ ប្រក. សហវ. ហ ស្តីពីការរៀបចំអង្គការគ្រួតពិនិត្យហិរញ្ញវត្ថុ ៤២៣

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៦-០២-១៩៩៦ ប្រកាសលេខ១០២ ភរ. ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន SERIKA Co. LTD ធ្វើអាជីវកម្មខ្សាច់ស នៅតំបន់តាម៉ាន់ - ពាមកាំង ក្នុងខេត្តកោះកុង ៤២៦

២៣-២-១៩៩៦ ប្រកាសលេខ ១១៥ ផក. ប្រក អនុញ្ញាតឱ្យលោក ជៀប តា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម ៤២៨

២៣-២-១៩៩៦	ប្រកាសលេខ ១១៦ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី ជា ថៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦៥ សេះ	៤២៩
២៣-២-១៩៩៦	ប្រកាសលេខ ១១៧ ផក.ប្រក អនុញ្ញាតឱ្យលោក លឹម គឹមធី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើររោងជាងផលិតគ្រឿងសង្ហារឹម	៤២៩
២៣-២-១៩៩៦	ប្រកាសលេខ ១១៨ ផក.ប្រក អនុញ្ញាតឱ្យលោក ហុង សឹម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើររោងជាងផលិតគ្រឿងសង្ហារឹម	៤៣០
២៣-២-១៩៩៦	ប្រកាសលេខ ១១៩ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី កួយ គឹមហួរ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើររោងជាងផលិតគ្រឿងសង្ហារឹម	៤៣១
២៣-២-១៩៩៦	ប្រកាសលេខ ១២០ ផក.ប្រក អនុញ្ញាតឱ្យលោក ឈើវ ជុង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មស្លដែក	៤៣២
២៣-២-១៩៩៦	ប្រកាសលេខ ១២១ ផក.ប្រក អនុញ្ញាតឱ្យលោក តួច រាយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ	៤៣៣
២៣-២-១៩៩៦	ប្រកាសលេខ ១២២ ផក.ប្រក អនុញ្ញាតឱ្យលោក ប៊ិន ឈួន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ប្តូរទីតាំងកាត់ដេរសំលៀកបំពាក់	៤៣៤
២៣-២-១៩៩៦	ប្រកាសលេខ ១២៣ ផក.ប្រក អនុញ្ញាតឱ្យលោក នុក សុធា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ	៤៣៤
២៣-២-១៩៩៦	ប្រកាសលេខ ១២៤ ផក.ប្រក អនុញ្ញាតឱ្យលោក ហាវ លឹម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៤៣៥

២៩-២-១៩៩៦	ប្រកាសលេខ ១២៨ ផក.ប្រក អនុញ្ញាតឱ្យលោក គុង លី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតភេសជ្ជៈ	៤៣៦
២៩-២-១៩៩៦	ប្រកាសលេខ ១២៩ ផក.ប្រក អនុញ្ញាតឱ្យលោក HUANG YU LIU ជនជាតិចិនតៃវ៉ាន់ បើកដំណើរការសិប្បកម្មផលិតគ្រឿងអលង្ការក្រខ្សែ	៤៣៧
២៩-២-១៩៩៦	ប្រកាសលេខ ១៣០ ផក.ប្រក អនុញ្ញាតឱ្យលោក គួយ ពេងគ្រី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	៤៣៧
២៩-២-១៩៩៦	ប្រកាសលេខ១៣១ ផក.ប្រក អនុញ្ញាតឱ្យលោក យូរ ប៊ុនហៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ	៤៣៨
២៩-២-១៩៩៦	ប្រកាសលេខ១៣២ ផក.ប្រក អនុញ្ញាតឱ្យលោក ហួន ប៊ុនលីម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ	៤៣៩

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួង ពត៌មាន

ប្រកាស

២២-០២-១៩៩៦	ប្រកាសលេខ ០៦៤/៩៦ ពម.ប្រក អនុញ្ញាតឱ្យសាជីវកម្មផ្សាយសម្លេងរបស់អង់គ្លេស «ប៊ី ប៊ី ស៊ី» បើកស្ថានីយ៍វិទ្យុផ្សាយសម្លេងបន្ត	៤៤០
២៣-០២-១៩៩៦	ប្រកាសលេខ ០៦៥/៩៦ ពម.ប្រក អនុញ្ញាតឱ្យអ្នកស្រី ស្រី វុទ្ធី បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « ងួន វុទ្ធី »	៤៤១
២៨-០២-១៩៩៦	ប្រកាសលេខ ០៦៨/៩៦ ពម.ប្រក អនុញ្ញាតឱ្យបន្តបោះពុម្ពផ្សាយទស្សនាវដ្តី ឈ្មោះ « សហជីពកម្ពុជា »	៤៤៣

២៩-០២-១៩៩៦	ប្រកាសលេខ ០៧១/៩៦ ពម.ប្រក អនុញ្ញាតជូនលោក ម៉េង ហ៊ាង បើកអាជីវកម្មរោងពុម្ពឈ្មោះ « ពន្លឺខ្មែរ »	៤៤៤

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

-០២-១៩៩៦	ប្រកាសលេខ ១៥៨ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ បានលុង ទៅជាវិទ្យាល័យ សម្តេចឪ សម្តេចម៉ែ ស្ថិតនៅក្នុង ស្រុកបានលុង ខេត្តរតនគិរី	៤៤៦
២០-០២-១៩៩៦	ប្រកាសលេខ ១៦៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ពោធិវង្ស	៤៤៧
២០-០២-១៩៩៦	ប្រកាសលេខ ១៦៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ស្មៅខ្ចី	៤៤៨
២៩-០២-១៩៩៦	ប្រកាសលេខ ១៦៩ អយក.ប្រក កែប្រែប្រការ ២ នៃប្រកាស លេខ ១៦៧៧ អយក.ប្រក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការប្តូរឈ្មោះមជ្ឈមណ្ឌលអប់រំពហុបច្ចេកទេសតំរង់ទិសវិជ្ជាជីវៈ និងរោងជាងផលិតសំភារៈសិក្សា	៤៥០
២៣-០២-១៩៩៦	ប្រកាសលេខ ១៧០ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ខ្នារ	៤៥១
២៨-០២-១៩៩៦	ប្រកាសលេខ ១៧៨ អយក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាកំរិត ១	៤៥២

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

ប្រកាស

២៦-០២-១៩៩៦	ប្រកាសលេខ ២១៩ កទច.ប្រក ស្តីពីការចេញច្បាប់អនុញ្ញាតប្រកបអាជីវកម្មសណ្ឋាគារ - ផ្ទះសំណាក់	៤៦១

២៦-០២-១៩៩៦ ប្រកាសលេខ ២២០ កទច.ប្រក ស្តីពីការចេញច្បាប់អនុញ្ញាត ប្រកបអាជីវកម្មភោជនីយដ្ឋាន រង្គសាល ឱស្ថតែត ការ៉ាអូខេ ៤៦៤

២៦-០២-១៩៩៦ ប្រកាសលេខ ២២១ កទច.ប្រក ស្តីពីការធ្វើអាជីវកម្មនៅរមណីយដ្ឋាន ទេសចរណ៍ ៤៦៨

២៦-០២-១៩៩៦ ប្រកាសលេខ ២២២ កទច.ប្រក ស្តីពីការចេញលិខិតអនុញ្ញាត ជូនមគ្គុទ្ទេសក៍ទេសចរ ៤៧១

២៦-០២-១៩៩៦ ប្រកាសលេខ ២២៣ កទច.ប្រក ស្តីពីការប្រកបអាជីវកម្មដឹក ជញ្ជូនទេសចរ តាមយានយន្ត ៤៧៥

២៦-០២-១៩៩៦ ប្រកាសលេខ ២២៤ កទច.ប្រក ស្តីពីការចេញច្បាប់អនុញ្ញាត ប្រកបអាជីវកម្ម នាវាដឹកជញ្ជូនទេសចរ ៤៧៩

៦ - ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសម្រេច

២១-០២-១៩៩៦ សេចក្តីសម្រេចលេខ ៤៥/៩៦ កធស អនុញ្ញាតជាគោលការណ៍ ឱ្យបើកស្នាក់ការថ្វាយបង្គំ នៃសាសនាគ្រីស្ទរបស់សហព័ន្ធគ្រីស្ទ បរិស័ទខ្មែរ « ព្រះវិហារតាហោរ » ៤៨៣

២១-០២-១៩៩៦ សេចក្តីសម្រេចលេខ ៤៦/៩៦ កធស អនុញ្ញាតឱ្យអង្គការ « សុខមាលភាពព្រះពុទ្ធសាសនា » បើកការិយាល័យបណ្តោះ អាសន្នមួយកន្លែង ៤៨៤

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០២៩៦/០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស
អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ
បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌល សកម្មភាពកំចាត់មីនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីសមាសភាពក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សម សុត្ថា** ជានាយក មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដែលមានឋានៈស្មើអគ្គនាយក ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ រាជរដ្ឋាភិបាលកម្ពុជា

ប្រកាសបង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សេរី កុសល** ជាបេសកជនពិសេសរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានន្តរសក្តិ ជាឧត្តមសេនីយ៍ទោ និងមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ហួត ម៉ុនលី** ជាឧត្តមសេនីយ៍ទោ នៃកងយោធពល ខេមរភូមិន្ទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋ

មន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

- យោងព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : អនុញ្ញាតឱ្យ ឯកឧត្តម ខៀវ រ៉ាដា លាលែងចេញពីមុខដំណែង ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

II - ទីស្ដីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ០៩ អនក្រ.បក

ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង

ពិនិត្យទាយតំលៃជ្រើសរើសឈើគំរោងការ

បូមដី បាតទន្លេ-ស្ទឹងព្រែក និង បឹង

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ ១០៩៤-៨៣ នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤-៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណូមពរចាំបាច់នៃការងារ

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយទទួលបន្ទុកការងារពិនិត្យ សិក្សាវាយតំលៃជ្រើសរើសលើកយោបល់ជូននាយករដ្ឋមន្ត្រីទាំងពីរសំរេច លើគំរោងការបូមដីបាតទន្លេ-ស្ទឹង , ព្រែក និង បឹង ។

សមាសភាពគណៈកម្មាធិការនេះមានដូចតទៅ :

- ឯកឧត្តម **វ៉ុង សឿន** ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ជាប្រធាន
- ឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
- ឯកឧត្តម **វេង សេរីវុឌ្ឍ** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

-ឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាសមាជិក

-ឯកឧត្តម **ឈឹម សៀកឡេង** ប្រតិភូរាជរដ្ឋាភិបាល ជាសមាជិក

-ឯកឧត្តម **ហោច ចន្ទ្របុិនឆាត** តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ជាសមាជិក

-ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

-ឯកឧត្តម **អ៊ុម ឈុនលឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក

-ឯកឧត្តម **ហ៊ុល ឈឹម** អនុរដ្ឋលេខាធិការក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ជាសមាជិក

-លោក តំណាងក្រសួងការពារជាតិ ជាសមាជិក

មាត្រា ២ : គណៈកម្មការនេះមានភារកិច្ចទទួល និងសិក្សាពិនិត្យលើសំណើសុំ នៃគំរោងការបូមដីចាតទន្លេ ស្ទឹង ព្រែក និងបឹងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រៀបធៀបជ្រើសរើស និង ផ្ទៀងផ្ទាត់លើគំរោង អភិវឌ្ឍន៍តំបន់ផ្សេងៗ និងគំរោងដែលមានស្រាប់ និង ស្នើជាយោបល់ថ្វាយ និងជូននាយករដ្ឋមន្ត្រីសំរេច ។

មាត្រា ៣ : ក្រោយពីមានការសំរេចជាគោលការណ៍គណៈកម្មការនេះ មានភារកិច្ចរៀបចំពិនិត្យ លំអិត និងចុះហត្ថលេខាលើកិច្ចសន្យាជាមួយក្រុមហ៊ុន វិនិយោគដែលត្រូវជ្រើសរើសក្នុងនាមរាជរដ្ឋាភិបាល ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ២៦ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផលនានាជា ប្រយោជន៍សាធារណៈនៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយ « មាស » ស្ថាបនាជាតិ :

១-លោកវរសេនីយ៍ឯក **ម៉ៅ តិរុណ** បរិច្ចាគទឹកប្រាក់ ៨៤.១៦០.០០០៛

២-លោក **ឌន ឡឿន** បរិច្ចាគទឹកប្រាក់ ៥៥.០០០.០០០៛

៣-លោក DINY VAN BRUGGEN.MD នៃអង្គការស្ពានហូឡង់ បរិច្ចាគទឹកប្រាក់ ២៣.៧៨០ ដុល្លារអាមេរិក

៤-លោក **ង៉ោ ទ្វី** បរិច្ចាគទឹកប្រាក់ ១១.៥០០ ដុល្លារអាមេរិក

៥–លោក **ម៉ក់ លីមហុង** បរិច្ចាគទឹកប្រាក់ ១១.៥០០ ដុល្លារអាមេរិក

៦–លោក **ហ៊ាន ឝុយ** បរិច្ចាគទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក

ខ–មេដាយ « ប្រាក់ » ស្ថាបនាជាតិ :

១–លោក **សួន ឈាងលី** បរិច្ចាគទឹកប្រាក់ ៥.៣៥៧ ដុល្លារអាមេរិក

គ–មេដាយ « សិរិទ្ធិ » ស្ថាបនាជាតិ :

១–លោក **ឆាយ គីមសុន** បរិច្ចាគទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

២–លោក **ទួន សារ៉ុន** បរិច្ចាគទឹកប្រាក់ ៥.០០០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ២៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ជូនសប្បុរសជន ១២ រូប ដែលបានឧបត្ថម្ភថវិកាជួយកសាងអាគារសិក្សាសម្តេច **ហ៊ុន សែន** នៅខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយ មាស ស្ថាបនាជាតិ :

១-ឯកឧត្តម **ហុក ឡុងឌី** និង លោកជំទាវ ឧបត្ថម្ភថវិកា ២៣.៩៧០ ដុល្លារអាមេរិក

២-លោក **តូ នី** ឧបត្ថម្ភថវិកា ២៥.០០០ ដុល្លារអាមេរិក

៣-លោក **ទេ គីរ** ឧបត្ថម្ភថវិកា ១៥.០០០ ដុល្លារអាមេរិក

៤-លោក **នូច សម្បត្តិ** ឧបត្ថម្ភថវិកា ១០.០០០ ដុល្លារអាមេរិក

៥-លោកស្រី **សោម សុផល** ឧបត្ថម្ភថវិកា ១០.០០០ ដុល្លារអាមេរិក

៦-លោក **ម៉ែន សារុន** ឧបត្ថម្ភថវិកា ១០.០០០ ដុល្លារអាមេរិក

ខ-មេដាយ ប្រាក់ ស្ថាបនាជាតិ :

១-លោក **សោម សាន្ត** ឧបត្ថម្ភថវិកា ៦.០០០ ដុល្លារអាមេរិក

២-លោក **សែន ណារិន** ឧបត្ថម្ភថវិកា ៦.០០០ ដុល្លារអាមេរិក

៣-លោក **សែ ម៉ាន់** ឧបត្ថម្ភថវិកា ៥.០០០ ដុល្លារអាមេរិក

៤-លោក **ឌែ ហុកឈួន** ឧបត្ថម្ភថវិកា ៥.០០០ ដុល្លារអាមេរិក

គ-មេដាយ សំរិទ្ធស្ថាបនាជាតិ :

១-លោក **គង់ ថ្លៃច** ឧបត្ថម្ភថវិកា ៣.០០០ ដុល្លារអាមេរិក

២-លោក **ម៉ារ ឈឺន** ឧបត្ថម្ភថវិកា ៣.០០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ២៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិជូនចំពោះអង្គការអន្តរជាតិ និង សប្បុរសជនដែលបានជួយកសាងវិស័យអប់រំ និង សង្គមកិច្ចក្នុងរាជធានីភ្នំពេញ ដូចមានខាងក្រោមនេះ ៖

១-សមាគមឪពុកម្តាយចិញ្ចឹម កុមារកម្ពុជា (ASPECA) ជួយកសាងអាគារសិក្សានៅសាលាបឋមសិក្សាជ័យជំនះ អស់ទឹកប្រាក់ ៥៩.០៧៩ ដុល្លារអាមេរិក ។

២-ឧកញ៉ា ឆោ ស៊ុនឈី ជួយកសាងអាគារសិក្សានៅសាលាបឋមសិក្សាជ័យជំនះអស់ទឹកប្រាក់ ៥០.៨០០ ដុល្លារអាមេរិក ។

៣-អង្គការ ASPECA ជួយកសាងអាគារថែទាំកុមារកំព្រា នៅសាលាបឋមសិក្សាបឹងត្របែកខាងត្បូង អស់ទឹកប្រាក់ ៥៨.៩៩២ ដុល្លារអាមេរិក ។

៤-អង្គការក្រុមកំលាំងយុវជនជប៉ុន (JHP) ជួយកសាងអាគារសិក្សានៅសាលាបឋមសិក្សាព្រែកប្រាលើ អស់ទឹកប្រាក់ ២៥.៤៦៨ ដុល្លារអាមេរិក។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ២៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិជូនចំពោះលោក **គិត ម៉េង** នាយកក្រុមហ៊ុន រ៉ូយ៉ាល់ហ្គ្រុប ដែលបានធ្វើអំណោយ ម៉ាស៊ីន ហ្វូតូកូពីពណ៌ ចំនួន ០២ គ្រឿង មានតំលៃ ៥០.០០០ ដុល្លារអាមេរិក ថ្វាយសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ សំរាប់ដាក់ប្រើប្រាស់ក្នុងខុទ្ទកាល័យរបស់ព្រះអង្គផ្ទាល់ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេច ក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធ ផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៣០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិជូនចំពោះលោក **គិត មេង** ប្រធានក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប ដែលបានធ្វើអំណោយ ម៉ាស៊ីន ហ្វូតូកូពីពណ៌ ចំនួន ០២ គ្រឿង មានតំលៃ ៥០.០០០ ដុល្លារអាមេរិក ជូនសម្តេចនាយករដ្ឋមន្ត្រីទី ២ សំរាប់ដាក់ប្រើប្រាស់ក្នុងខុទ្ទកាល័យរបស់សម្តេច ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សារាចរ

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សារាចរលេខ : ០៣ សរ

ស្តីពីការធ្វើផ្លាកលេខយានយន្តគ្រប់ប្រភេទ

- យោងអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី ១០/៩/១៩៨៩ ស្តីពីការផ្ទេរការងារចុះបញ្ជីប័ណ្ណសំគាល់ផ្លាកលេខយានយន្ត ប័ណ្ណបើកបរ លិខិតអនុញ្ញាតធ្វើអាជីវកម្ម ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និង ការគ្រប់គ្រងយានជំនិះគ្រប់ប្រភេទ ពីក្រសួងមហាផ្ទៃ មកក្រសួងគមនាគមន៍ ដឹកជញ្ជូន និង ប្រៃសណីយ៍
- យោងស្មារតីរបស់អង្គប្រជុំអន្តរក្រសួង នៅថ្ងៃទី ២៦ ខែ តុលា ១៩៩៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។
- ដើម្បីធានាបាននូវការឯកភាពជាទូទៅ ក្នុងការផ្តល់ផ្លាកលេខយានយន្តគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា និង ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនូវមធ្យោបាយទាំងនោះ ដែលធ្វើចរាចរ និង ដឹកជញ្ជូនទំនិញគ្រប់ប្រភេទតាមផ្លូវសាធារណៈអោយមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ÷

១-មិនអនុញ្ញាតអោយរថយន្តឯកជន ទោះជាមានឋានៈណាក៏ដោយបានពាក់ផ្លាកលេខសញ្ញា «ខម» « នប » ឬ « មផ » ចាប់ពីពេលនេះតទៅ ។

២-ចំពោះរថយន្តរបស់ឯកជន ដែលក្រសួងការពារជាតិបានផ្តល់ផ្លាកលេខសញ្ញា « ខម » និង ក្រសួងមហាផ្ទៃបានផ្តល់ផ្លាកលេខ « នប » ឬ « មផ » កន្លងមកហើយ ម្ចាស់រថយន្តត្រូវទៅសុំប្តូរផ្លាកលេខស៊ីវិលនៅក្រសួងសាធារណការ និងដឹកជញ្ជូនមកប្រើប្រាស់ជំនួសវិញ ចាប់ពីថ្ងៃចេញសារាចររបស់រាជរដ្ឋាភិបាលនេះតទៅ ។

៣-ចំពោះមន្ត្រីយោធា នគរបាល ថ្នាក់ឧត្តមសេនីយ៍ ឬ វរសេនីយ៍ ដែលប្រើប្រាស់រថយន្តពាក់ផ្លាក លេខ ខម នប ឬ មផ ដោយពុំទាន់បង់ពន្ធនាំចូល ហើយពុំមានប្រាក់បង់ពន្ធនៅពេលទៅប្តូរយកផ្លាកលេខស៊ីវិល ក៏ប៉ុន្តែត្រូវការមធ្យោបាយជិះសំរាប់បំរើការ

ងារ រាជរដ្ឋាភិបាល និង ពិនិត្យពិចារណាលើការស្នើរលើកលែងបន្ទុយពន្ធ ជូនដោយតំរូវអោយក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃលើកសំណើ ដើម្បីសុំបន្ធូយពន្ធមករាជរដ្ឋាភិបាល ។ ប៉ុន្តែករណីនេះអាចធ្វើជូនបានចំពោះរថយន្តតែមួយគ្រឿងប៉ុណ្ណោះចំពោះមន្ត្រីយោធាឬ នគរបាលមួយនាក់ ដែលខះខាតពិតប្រាកដហើយដែលរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃទទួលស្គាល់ក្នុងបញ្ជីឈ្មោះដែលកំរិតយ៉ាងច្បាស់លាស់ ។ ក្រោយពីមានគោលការណ៍បន្ធូយពន្ធពីរាជរដ្ឋាភិបាលហើយ រថយន្តខាងលើនេះត្រូវប្រើប្រាស់ផ្លាកលេខស៊ីវិលនៅ ក្រសួងសាធារណការ និង ដឹកជញ្ជូនវិញ ។

៤–លេខផ្លាកលេខ « ខម » អាចរក្សាទុកបានសំរាប់តែយានយន្តរបស់កងយោធពលខេមរភូមិន្ទដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ ហើយផ្លាកលេខ« នប »សំរាប់តែយានយន្តរបស់នគរបាលជាតិ ដែលជាកម្មសិទ្ធិរបស់អង្គភាពនគរបាលជាតិតែប៉ុណ្ណោះ ពោលគឺពុំមែនជាយានយន្តរបស់បុគ្គល ហើយដែលមានលាបពណ៌ជាលក្ខណៈសំគាល់នៅលើយានយន្តពាក់លេខផ្លាកលេខ « ខម » ផ្លាកលេខ« នប » ទាំងនេះផង ។ ចំពោះរថយន្តផ្សេងទៀតរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ដែលគ្មានលាបពណ៌ជាលក្ខណៈសំគាល់ គឺត្រូវប្រើផ្លាកលេខរាជការ ឬ រាជរដ្ឋាភិបាលដូចក្រសួងស្ថាប័ន នានា ។

៥–ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវបញ្ឈប់ការផ្តល់ផ្លាកលេខរថយន្ត « ខម » « នប » អោយរថយន្តឯកជនចាប់ពីពេលនេះតទៅ ហើយត្រូវរៀបចំនូវសញ្ញាផ្លាកលេខ « ខម » « នប » ជាថ្មីដោយមានលក្ខណៈសំគាល់ពិសេសមិនអាចក្លែងបន្លំបាន សំរាប់ប្រកាសអោយទទួលស្គាល់ និង ប្រើប្រាស់ទូទាំងប្រទេស ។

–ចំពោះរថយន្តដែលបានបង់ពន្ធរួចហើយ តែប្តូរលេខមិនទាន់ដោយហួសកាលបរិច្ឆេទ ដែលក្រសួងសាធារណការ និង ដឹកជញ្ជូនបានកំណត់ ក៏ត្រូវធ្វើស្ថិតិដោយឡែកដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

៦–ចំពោះយានយន្តដែលគ្មានពាក់ផ្លាកលេខ ក្រសួងមានសមត្ថកិច្ចត្រូវចាប់ពិន័យអោយបានតឹងរឹង ចាប់ពីពេលដែលបានទទួលសារាចរនេះតទៅ ។

៧-ចំពោះរថយន្តដែលប្រើផ្លាកលេខរបស់រាជការ សាមីក្រសួងត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចេញសងនូវការខូចខាតដល់ជនរងគ្រោះ ប្រសិនបើមានគ្រោះថ្នាក់អ្វីមួយកើតឡើង ។ ប្រធានស្ថាប័ននីមួយ ៗ ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យ កុំអោយមានបញ្ហាយករថយន្តឯកជនពាក់ផ្លាកលេខ រាជការ ។

៨-ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួងមហាផ្ទៃអោយបានល្អ និង ទាន់ពេលវេលា នៅពេលដែលក្រសួងមហាផ្ទៃត្រូវការស្រាវជ្រាវលេខយានយន្តពាក់ព័ន្ធក្នុងការប្រព្រឹត្តិបទល្មើសអ្វីមួយ ។

៩-ក្រៅអំពីផ្លាកលេខ « ខម » ឬ « នប » ដែលមានលក្ខណៈកំណត់ក្នុងចំណុច ៤ និង ៥ ខាងលើនេះ ការកិច្ចចេញផ្លាកលេខផ្សេងទៀត ត្រូវប្រមូលផ្តុំនៅក្រសួងសាធារណការ និង ដឹកជញ្ជូន ។

១០-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំគោលការណ៍មួយចំនួន ដើម្បីអោយអ្នកលក់យានយន្តគ្រប់ប្រភេទត្រូវតែបង់ពន្ធជាមុន ។ នឹងដាក់ចេញលក់នៅលើទីផ្សារក្នុងប្រទេស ។

ក្រោយពេលទទួលបានសារាចរនេះ រាជរដ្ឋាភិបាល សូមគ្រប់ក្រសួង ស្ថាប័នក្នុងព្រះរាជាណាចក្រកម្ពុជា យកចិត្តទុកដាក់អនុវត្តខ្លឹមសារនៃសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់យ៉ាងមាំថា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងសាធារណការ និងដឹកជញ្ជូន ខិតខំយកចិត្តទុកដាក់ចាត់ចែង អនុវត្តតាមខ្លឹមសារសារាចរនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង មានប្រសិទ្ធភាព ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សារាចរណែនាំលេខ : ០១ សរណន
ស្តីពីការរៀបចំទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ ១៩៩៦
ខួបលើកទី ៨៦ នៅគ្រប់ក្រសួង ស្ថាប័ន និង ខេត្ត–ក្រុង
ទូទាំងព្រះរាជាណាចក្រកម្ពុជា

* * *

– ដោយយល់ឃើញថា ក្រោមព្រះរាជកិច្ចដឹកនាំ និង ម្លប់ដ៏ត្រជាក់នៃព្រះមហាក្សត្រព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** និង សម្តេចព្រះ រាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** នៃកម្ពុជា នារីកម្ពុជាគ្រប់មជ្ឈដ្ឋានរួបរួមគ្នាប្រារព្ធទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ ១៩៩៦ ដែលជាខួប លើកទី ៨៦ នៅថ្ងៃទី ៦–៧– ខែ មីនា ឆ្នាំ ១៩៩៦ ខាងមុខនេះ ។

– ដោយមានបំណងរួម ក្នុងការលើកស្ទួយសិទ្ធិនារី តាមសកម្មភាពជាក់ស្តែងឆ្ពោះទៅរកទិសដៅសំខាន់ គឺ ÷

ប្រមូលកំលាំងនារីខ្មែរ រួមសាមគ្គីជុំវិញព្រះរាជបល្ល័ង្ក ការពារសិទ្ធិនារីក្នុងគ្រួសារ និងក្នុងសង្គមជាតិ បង្កើនតួនាទីក្នុងការកសាង និង អភិវឌ្ឍន៍ជាតិក្នុងឆ្នាំ ១៩៩៦ និងតទៅអនាគត ។

ដើម្បីអបអរសាទរបុណ្យទិវានារីអន្តរជាតិ ៨ មីនា រាជរដ្ឋាភិបាល សូមធ្វើការណែនាំចំពោះគ្រប់ ក្រសួង ស្ថាប័ន និង អាជ្ញាធរខេត្ត–ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវយកចិត្តទុកដាក់ក្នុងការផ្តល់លទ្ធភាព និងជួយឧបត្ថម្ភដល់តំណាងការពារផលប្រយោជន៍នារីរបស់ក្រសួង ស្ថាប័នសាមី អោយចូលរួមធ្វើសកម្មភាព និង តាំងពិព័រណ៍នៅកន្លែងប្រមូលផ្តុំសំរាប់ប្រារព្ធពិធី ០៨ មីនា ដែលរៀបចំដោយក្រសួងកិច្ចការនារី និង ជួយឧបត្ថម្ភប្រធានមន្ទីរកិច្ចការនារីខេត្ត–ក្រុង ក្នុងការប្រារព្ធពិធីបុណ្យទិវានារីអន្តរជាតិ ៨ មីនា នៅតាមខេត្ត–ក្រុង នីមួយ ។ នាពេលខាងមុខនេះ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង ត្រូវចាត់ចែង ផ្សព្វផ្សាយ និង អនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៤៨ ប្រក.សហវ.ហ

ស្តីពីការរៀបចំរចនាការគ្រួតពិនិត្យហិរញ្ញវត្ថុ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** លេខ១០៩៤ .៨៣ នស រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាស ភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញា ទូទៅនៃគណនេយ្យសាធារណ
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកានៅតាមក្រសួងខេត្ត - ក្រុង - ក្រុងស្វយ័ត រាជធានីភ្នំពេញនិងអង្គការសាធារណៈរដ្ឋបាល

សម្រេច

ប្រការ ១ : អនុលោមតាមបទបញ្ញានៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរេចបង្កើតឡើងនូវអង្គភាពអភិបាលហិរញ្ញវត្ថុ តាមក្រសួងស្ថាប័នកណ្តាលនិងអង្គភាពទាំងឡាយក្នុងខេត្ត-ក្រុង ព្រមទាំងអង្គការសាធារណៈរដ្ឋបាលនានានៅក្រោមចំណុះ សំរាប់អនុវត្តកិច្ចប្រតិបត្តិការត្រួតពិនិត្យហិរញ្ញវត្ថុ ។

បេសកកម្មត្រួតពិនិត្យហិរញ្ញវត្ថុត្រូវគ្រប់គ្រងដោយនាយកដ្ឋានហិរញ្ញកិច្ច ស្ថិតនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ប្រការ ២ : នាយកដ្ឋានហិរញ្ញកិច្ច មានភារកិច្ច :

- គ្រប់គ្រងសកម្មភាព សម្របសម្រួល និងតាមដានការអនុវត្តន៍របស់អភិបាល ហិរញ្ញវត្ថុ ។

- ប្រមូលផ្តុំពត៌មានដែលបានពីអភិបាលហិរញ្ញវត្ថុ លើកិច្ចសន្យាចំណាយ និងការប្រើប្រាស់ឥណទាន ដើម្បីកសាងឡើងជារៀងរាល់ខែ នូវគណនេយ្យរួមនៃកិច្ចសន្យាមួយសំរាប់ធ្វើការផ្ទៀងផ្ទាត់ជាមួយ គណនេយ្យរដ្ឋបាលរបស់អាណាប័ក និងជាមួយគណនេយ្យចំណាយដែលធ្វើឡើងដោយផ្នែកនានារបស់រតនាគារជាតិ ។
- ស្វែងយល់អំពីការខ្វែងយោបល់គ្នា ដែលអាចកើតមានឡើងរវាងអភិបាលហិរញ្ញវត្ថុ និងអាណាប័ក ដើម្បីលើកសំណើដោះស្រាយសមស្របជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរេច ។
- ធ្វើសំយោគរបាយការណ៍ប្រចាំត្រីមាសរបស់អភិបាលហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍លទ្ធកម្មសាធារណៈ និងការប្រតិបត្តិនីតិវិធីនៃកិច្ចសន្យាក្នុងគំរោង ដើម្បីលើកសំណើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីវិធានការចាំបាច់ ដែលត្រូវប្រកាន់យកសំដៅបំបាត់ចោលនូវការខ្វះខាតទាំងឡាយដែលកត់សំគាល់ឃើញជាយថាហេតុ ។
- កសាងកម្មវិធីត្រួតពិនិត្យតាមក្រោយ ចំពោះអភិបាលហិរញ្ញវត្ថុ អំពីល័ក្ខខ័ណ្ឌ នៃការអនុវត្តន៍ប្រសិទ្ធភាពចំណាយព្រមទាំងស្នើឡើង នូវវិធានការកែតំរូវចាំបាច់ ។
- រៀងរាល់ឆ្នាំ ដោយផ្អែកលើរបាយការណ៍របស់អភិបាលហិរញ្ញវត្ថុតាមផ្នែក ត្រូវធ្វើរបាយការណ៍រួមស្តីពីលទ្ធផលនៃកិច្ចប្រតិបត្តិត្រួតពិនិត្យការអនុវត្តន៍ថវិកា ព្រមទាំងលើកសំណូមពរកែទំរង់ដើម្បីកែលំអការអនុវត្តន៍នោះ ។
- ចាត់ចែងរាល់ការសិក្សាផានាពង្រឹងដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ប្រការ ៣ : ខុទ្ទកាល័យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរ . នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស . នាយកដ្ឋានវិនិយោគមូលដ្ឋាន នាយកដ្ឋានទ្រព្យរដ្ឋ មន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុ

ខេត្ត-ក្រុង ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ១០២ ឧក ប្រក

អនុញ្ញាតឱ្យក្រុមហ៊ុន SERIKA Co Ltd ធ្វើអាជីវកម្មខ្សាច់ ស នៅតំបន់តាម៉ាន់ ពាមរាំង ក្នុងខេត្ត កោះកុង

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មខ្សាច់ស ក្នុងខេត្តកោះកុង របស់គណៈកម្មាធិការ វិនិយោគកម្ពុជា លេខ ១០២៣/៩៥ គវក ចុះថ្ងៃទី ២៧-១១-១៩៩៥
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនធ្វើអាជីវកម្មខ្សាច់សនៅតំបន់ តាម៉ាន់ ពាមរាំងក្នុងខេត្ត កោះកុង ចុះថ្ងៃ ០៨ ខែធ្នូ ឆ្នាំ ១៩៩៥

– បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មខ្សាច់សរបស់ក្រុមហ៊ុន SERIKA CO Ltd លេខ ០៩/៩៥ សរក ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សម្រេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន SERIKA CO Ltd មានអាសយដ្ឋានផ្ទះលេខ ១០៦ ផ្លូវលេខ ៣១០ សង្កាត់បឹងកេងកងទី ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើ អាជីវកម្មខ្សាច់ស នៅតំបន់ **តាម៉ាន់ ពាមរាំង** ក្នុងខេត្តកោះកុង លើផ្ទៃដី ៣០ គីឡូម៉ែត្រក្រឡា មានកូអរដោនេដូចតទៅ ÷

ចំណុច	ខ្សែរយៈបណ្តោយ	ខ្សែរយៈទទឹង
A	103° 00'35"E	11° 37'11" N
B	103° 03'50"E	11° 37'11" N
C	103° 03'50"E	11° 34'22" N
D	103° 00'35"E	11° 34'22" N

ប្រការ ២ : ក្រុមហ៊ុន SERIKA CO Ltd ត្រូវដំណើការងារអាជីវកម្មខ្សាច់ស លើផ្ទៃដីដែលបានកំណត់នេះ ដោយធានាអនុវត្តតាមបច្ចេកទេសអាជីវកម្ម ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ២(ពីរ) ឆ្នាំ ។ ផុតកំណត់នេះក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើអាជីវកម្មខ្សាច់សបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនិងត្រូវដកហូតវិញដោយគ្មានលក្ខខ័ណ្ឌ ។

ប្រការ ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមន្ទីរនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកោះកុងប្រធានក្រុមហ៊ុនត្រូវ ទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រកាស លេខ ១១៥ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ឡៅ ឆា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ២២៩៦៩៦ ភ.ព ចុះថ្ងៃទី ២៩–៥–៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២០ ផ្លូវលេខ ២០៥ សង្កាត់ ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំង ក្រុមទី ៥ ភូមិអូរបែកក្អម សង្កាត់ ទឹកថ្លា ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ ៣ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ តុ ទូ ទ្វារ បង្អួច គ្រោងទ្វារ បង្អួច កៅអី ឈើ ការ៉ូ នីវ ឈើពិដាន ឈើក្រឡឹង និង សាឡុង ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីសហគ្រាសត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៤ : ម្ចាស់សហគ្រាសត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្ម របស់សហគ្រាស ផ្ញើជូនមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់សហគ្រាស ត្រូវ ធ្វើ ពាក្យស្នើសុំការអនុញ្ញាតបន្តផលិតកម្មរបស់ឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាស លេខ ១១៦ ឧក. ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី ខាំ ខៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០០៥១៣៨ ត.ក ចុះថ្ងៃទី ១៥-៩-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិត្រាំ សង្កាត់រកាក្រៅ ទីរួមខេត្តតាកែវ ខេត្តតាកែវ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី ខាំ ខៅ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម -អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ១១៧ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក លឹម គឹមធី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៤០៥១ ភ.ព ចុះថ្ងៃទី ០៨-១១-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ អាចារ្យលាក់ ឃុំ អាចារ្យ លាក់ ស្រុក ស្ទឹងសែន ខេត្តកំពង់ធំ បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក លឹម គឹមធី ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ តុ ទូ កៅអី គ្រែ ទ្វារ បង្អួច ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់រោងជាង ផ្ញើមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ធំ ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ១១៨ ឧក .ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហុង ស៊ីម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៣០៥៥ ព.ស ចុះថ្ងៃទី ១០-៩-៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ក្តី ឃុំព្រៃកកាហ្វ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំង ដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **លឹម ហុងស៊ីម** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិ ដែលមានជាធរមាន។

ប្រការ ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈគុ ទូ កៅអី គ្រែ ទ្វារ បង្អួច ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្រប ច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់រោងជាង ផ្ញើមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ធំ ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១១៩ ឧក.ប្រកចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **គួយ គីមហួ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា អាស័យដ្ឋានបច្ចុប្បន្ន ភូមិ អាចារ្យលាក់ ឃុំអាចារ្យលាក់ ស្រុក ស្ទឹងសែន ខេត្តកំពង់ធំ បើកដំណើរការរោងជាងផលិតគ្រឿង សង្ហារឹម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **គួយ គីមហួ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងចក្រត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសាវវង្គៈគុ ទូ កៅអី គ្រែ ទ្វារ បង្អួច ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់ រោងជាង ផ្ញើមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត កំពង់ធំ ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ រោងជាងត្រូវធ្វើពាក្យ ការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើង ។

* * *

ប្រកាសលេខ ១២០ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **យឹម ដុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់ អត្តសញ្ញាណប័ណ្ណលេខ ២៤៤០ ៥០ ភ.ព ចុះថ្ងៃ ២៧-៧-៨៩ អាស័យដ្ឋាន បច្ចុប្បន្ន ដីឡូតិ៍លេខ ១៦ ផ្លូវលេខ ២៥៩ សង្កាត់ បឹងសាឡាង ខ័ណ្ឌទួល គោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មស្វដែក និង ផលិតការស្បែក ក្រប៊ី នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១២១ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក គូ រាយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០៣៥៣០៤ ក.ធ ចុះថ្ងៃទី០៩-១២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់ថ្ម ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្ត កំពង់ធំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក គូ រាយ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

* * *

ប្រកាសលេខ ១២២ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ចិន ឈួន** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩២៧៨៨ ក.ព ចុះថ្ងៃទី ២៨-៣-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៦៣ អឺ០ ផ្លូវកម្ពុជាក្រោម សង្កាត់ ផ្សារដេប៉ូទី ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ប្តូរទីតាំងសិប្បកម្មកាត់ដេរសំលៀក បំពាក់ " អន្តរជាតិ " ដែលមានទីតាំងផ្ទះលេខ ៣៥៣ អឺ០ ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ទៅកាន់ទីតាំងថ្មី ។

ប្រការ ២ : លោក **ចិន ឈួន** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការផលិតកម្មកាត់ដេរសំលៀកបំពាក់ «អន្តរជាតិ» លើទីតាំងថ្មីផ្ទះលេខ ៥៦៣ អឺ០ ផ្លូវលេខ ១២៨ សង្កាត់ ផ្សារដេប៉ូទី ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់ស្ថានុ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១២៣ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឱុត សុធា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៦៨៥៥ ក.ណ ចុះថ្ងៃទី ២៦-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិខ្ពបលើ ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **នុត សុធា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើង ។

* * *

ប្រកាសលេខ ១២៤ ឧ.ក ប្រក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហាច លឹម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០៦៩២០៧ ភ.ព ចុះថ្ងៃទី ២០-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២៥ ភូមិ ២០ ឧសភា សង្កាត់ ឯកភាព ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិ ប៉ោយយង់ ឃុំតាពូង ស្រុកបាត់ដំបង ខេត្ត បាត់ដំបង ។

ប្រការ ២ : លោក **ហាច លឹម** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្កលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ១២៨ ឧ.ក ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្មផលិតភេសជ្ជៈ **គុខ លី** សញ្ញា « ឡឺ វីស្សឌី LE WHISDI» ដែលមាន លោក **សៀន អាង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៩២២០២ ភ.ព ចុះថ្ងៃទី ១០-០២-១៩៩២ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥៩ អាអឺ០ ផ្លូវលេខ ១៤៣ សង្កាត់ បឹងកេងកងទី ៣ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការផលិតកម្ម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **សៀន អាង** ត្រូវរៀបចំសិប្បកម្មរបស់ខ្លួនអោយរួចស្រេចជាស្ថាពរ ក្នុងរយៈពេល ៣ ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈ ពេលកំណត់ ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : លោក **សៀន អាង** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលភេសជ្ជៈ **គុខ លី** សញ្ញា «ឡឺ វីស្សឌី LE WHISDI» ស្របតាមគំរូ និងផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើង ។

* * *

ប្រកាស លេខ ១២៩ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្ម ផលិតកម្មគ្រឿងអលង្ការក្រឡៃ « IMITATION JEWELRY» ដែលមានលោក HUANG YU LIU ជនជាតិ ចិន (តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ M 2409076 ចុះថ្ងៃទី ២៥-៩-៨៧ ជាតំណាងក្រុមហ៊ុន « WONDER JEWELERY CO LTD » អាស័យដ្ឋាន បច្ចុប្បន្ន ផ្ទះលេខ ២១៥ ផ្លូវលេខ ១៤៦ សង្កាត់ ទឹកល្អក់ទី ២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការផលិតកម្មនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ១៣០ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **គួយ សេងគ្រី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៤១៣៥ ក.ស្ត ចុះថ្ងៃទី ០១-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ក្របីត្រាំ ឃុំជង្រុក ស្រុក គងពិសី ខេត្ត កំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិ ស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង

ករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់សុខភាព ប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយ គ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ១៣១ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **យូរ ម៉ិនហៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៥៤៥៧ ក.ស្ន ចុះថ្ងៃទី ១៣-៦-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិតីរស្មី ឃុំ ព្រៃវំដួល ស្រុក ភ្នំស្រួច ខេត្ត កំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **យូរ ម៉ិនហៀង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ១៣២ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ហួន ម៉ុនលីម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០០៧២៨២ក.ស្ត ចុះថ្ងៃទី ១៤-០២-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិវត្តភ្នំ ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ហួន ម៉ុនលីម ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ១៣៣ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក ខា ឌួរ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២១៦៣៥០ ក.ស្ត ចុះថ្ងៃទី ៣០-០២-៩៤ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រៃកន្ទោច ឃុំទឹកល្អក់ ស្រុក គងពិសី ខេត្ត កំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ នៅក្នុងទីតាំង ភូមិ បឹងប្រស្រែ ឃុំព្រៃញាតិ ស្រុក គងពិសី ខេត្ត កំពង់ស្ពឺ ។

ប្រការ ២ : លោក ខា ឌួរ ត្រូវចាប់ផ្តើមដំណើការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៦៤/៩៦ ព.ម.ពសធ.ប្រក

អនុញ្ញាតឱ្យសាជីវកម្មផ្សាយសំលេងរបស់អង់គ្លេស

« ប៊ី.ប៊ី.ស៊ី » បើកស្ថានីយ៍វិទ្យុផ្សាយសំលេងបន្ត

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១ .១១.៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- ពិនិត្យលើសំណើសុំអនុញ្ញាតច្បាប់បើកស្ថានីយ៍វិទ្យុផ្សាយសំលេងបន្តពីសាជីវកម្ម ផ្សាយសំលេងរបស់អង់គ្លេស «ប៊ី ប៊ី ស៊ី » ទីក្រុងឡុងដុន ចុះថ្ងៃទី ១៩.៩.៩៤។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយសាជីវកម្មផ្សាយសំលេងរបស់អង់គ្លេស « ប៊ី ប៊ី ស៊ី » បើកស្ថានីយវិទ្យុផ្សាយសំលេងបន្តអេហ្វអឹម ១០០ មេហ្គាហឺត និងកំលាំងអនុភាពផ្សាយ ១ គីឡូវ៉ាត់ ស្ថិតនៅផ្ទះលេខ ១៧ ផ្លូវលេខ ៣០៦ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយត្រូវគោរពតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិ ឬសេចក្តីណែនាំខាង ផ្នែកសោតទស្សន៍ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាជីវកម្មផ្សាយសំលេងរបស់អង់គ្លេស នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកវិទ្យុជាតិ មន្ទីរពត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរពាក់ព័ន្ធត្រូវទទួល បន្ទុកអនុវត្តប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៦៥/ ៩៦ ព.ម.ឋសព.ប្រក

អនុញ្ញាតឱ្យលោកស្រី ស្រ៊ី ធុន្នី បើកសាជីវកម្ម

រោងពុម្ពដែលមានឈ្មោះ « ខ្ទុន ធុន្នី »

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ : ១២២៤.៩៤.ព.ម ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «ងួន វុទ្ធី» របស់អ្នកស្រី ស្រីវុទ្ធី ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស្រី វុទ្ធី** ស្ថិតនៅផ្ទះលេខ ៧០១ ផ្លូវលេខ ២៦១ ក្រុមទី ២០ សង្កាត់ទឹកល្អក់ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «ងួន វុទ្ធី» ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៧០៣ ផ្លូវលេខ ២៦១ សង្កាត់ទឹកល្អក់ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅ នឹងទំនៀមទំលាប់ សន្តិសុខសង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយសោតទស្សន៍ នៃ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគត្តិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៦៨/៩៦ ព.ម.ប្រក

អនុញ្ញាតឱ្យបន្តបោះពុម្ពផ្សាយទស្សនាវដ្តី

ឈ្មោះ « សហជីពកម្ពុជា »

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស.រកម.០៨៩៥.០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។
- បានឃើញសំណើរបស់លោក ហ៊ឹម គីរុណ ចាងហ្វាងព្រឹត្តិប័ត្រសហជីពកម្ពុជា ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបន្តបោះពុម្ពផ្សាយទស្សនាវដ្តីឈ្មោះ « សហជីពកម្ពុជា » ដោយមានលោក **ហ៊ឹម គីរុណ** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៤៥ ផ្លូវលេខ ៦៣ សង្កាត់បឹងកេងកង ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណប័ណ្ណ នៃទស្សនាវដ្តីរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ១០ ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចហើយស្នើប្រគល់ទស្សនាវដ្តីចំនួន

០៦ ច្បាប់ រៀងរាល់លេខ ចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងព័ត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : លោក **ហ៊ុម គីរុណ** ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌល ព័ត៌មាន នៃក្រសួងព័ត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៧១/៩៦ ព.ម.ប្រក

អនុញ្ញាតជូនលោក ម៉េង ហ៊ាង បើករោងពុម្ព

រោងពុម្ពឈ្មោះ « ពន្លឺខ្មែរ »

រដ្ឋមន្ត្រី ក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតជូនដំណឹងរបស់ក្រសួងព័ត៌មានលេខ ១២២៤-៩៤. ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។

– យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «ពន្លឺខ្មែរ» របស់លោកម៉េង ហ៊ាង ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

សម្រេច

ប្រការ ១ : អនុញ្ញាតជូនលោក **ម៉េង ហ៊ាង** ស្ថិតនៅផ្ទះលេខ ១០៧ ផ្លូវលេខ ២១៧ ក្រុមទី ៣៣ សង្កាត់អូរឫស្សី ៣ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកអាជីវកម្មរោង ពុម្ពដែលមានឈ្មោះ «ពន្លឺខ្មែរ » ទីតាំងស្ថិតនៅផ្ទះលេខ ១៩ E0 ផ្លូវលេខ ១០៩ ក្រុមទី ៨ សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់សន្តិសុខសណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាម៉ីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជា ធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរពតិមានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៥៨ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ វិទ្យាល័យបានលុង ទៅជាវិទ្យាល័យ

សម្តេចឪ—សម្តេចម៉ែ ស្ថិតនៅក្នុងស្រុក បានលុង ខេត្តរតនគិរី

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

– បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ។

– យោងលិខិតរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តរតនគិរី លេខ ៥៦១/៩៥ អយក.សណ ចុះថ្ងៃទី ២៧–១១–៩៥ ។

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យបានលុង បច្ចុប្បន្នជា «វិទ្យាល័យ **សម្តេចឪ - សម្តេចម៉ែ**» ចាប់ពីបវេសនកាល ឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី និង

នាយកវិទ្យាល័យ សម្ដេចឪ សម្ដេចម៉ែ មានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៦៣ អយក.ប្រក

ស្ដីពីប្ដូរឈ្មោះសាលាបឋមសិក្សាពោធិចន្ទ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤ ។
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្ដីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ។
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្ដីពីការកំណត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំយុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង លេខ ៩០-៩៥ ចុះថ្ងៃទី ១៤-១០-៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំយុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្តូរឈ្មោះសាលាបឋមសិក្សាពោធិវង្ស នៅភូមិពោធិវង្ស ឃុំថ្កូវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មកជា « **សាលាបឋមសិក្សា សម្តេចម៉ែពោធិវង្ស**» ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំយុវជន និង កីឡា ប្រធាននាយកដ្ឋាន ចាត់តាំង ប្រធាននាយកដ្ឋាន ផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ព្រៃវែង នាយកសាលាបឋមសិក្សាសម្តេចម៉ែ-ពោធិវង្ស មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តូច ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៦៤ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ស្ទោងខ្មែរ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ ៧ ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ ខែ ១១ ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្តីពីការកំណត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្ត តាកែវ លេខ ៦២១ អយក.តបឋម ចុះថ្ងៃទី ២៨-១១-៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡា ខេត្ត តាកែវ ប្តូរឈ្មោះសាលាបឋមសិក្សាស្មៅខ្ញី នៅឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ទៅជា « **សាលា បឋមសិក្សាចំនួសារុន–ស្មៅខ្ញី** » វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានបាត់តាំងប្រធាននាយកដ្ឋាន ផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត តាកែវ ប្រធានការិយាល័យ ស្រុកបាទី នាយកសាលាបឋមសិក្សា ចំនួសារុន– ស្មៅខ្ញី មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៦៩ អយក.ប្រក

កែប្រែប្រការ២ នៃប្រកាសលេខ ១៦៧៧ អយក.ប្រក

ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ របស់ក្រសួង

អប់រំយុវជន និង កីឡា

ស្តីពីការប្តូរឈ្មោះមជ្ឈមណ្ឌលអប់រំពហុបច្ចេកទេស

តំរង់ទិសវិជ្ជាជីវៈ និង រោងជាងជួសជុលសំភារៈសិក្សា

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ១០-៩៤-៩០ ន.ស.រ.ក.ត. ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ ២០៧ សសរ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ១៩៨៨ របស់គណៈកម្មាធិការប្រជាជនបដិវត្ត រាជធានីភ្នំពេញ ។
- បានឃើញសេចក្តីសំរេចលេខ ៨៦៤ សស ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩២ របស់គណៈកម្មាធិការប្រជាជនបដិវត្តរាជធានីភ្នំពេញ ។
- បានឃើញលិខិតលេខ ១០ សជណ.អវ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៣ របស់ ខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី ។
- យោងតាមសំណើរបស់មន្ទីរអប់រំយុវជន និង កីឡា រាជធានីភ្នំពេញ ។

សម្រេច

ប្រការ ១ : ប្រការ ២ នៃប្រកាសរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ១៦៧៧. អយក.ប្រក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៥ត្រូវបានកែប្រែដូចតទៅ :

ប្រការ ២ ថ្មី : សាខាមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា - ជប៉ុន ជាអង្គភាពចំណុះមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា–ជប៉ុន ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានបាត់តាំង នាយកដ្ឋានផែនការ ហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មន្ទីរអប់រំយុវជន និងកីឡា រាជធានីភ្នំពេញ មានភារកិច្ចរៀង ។ ខ្លួន អនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
គា សាហាន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៧០ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ខ្លារ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ ខែ ១១ ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ។
- បានឃើញអនុក្រឹត្យ លេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ១៩៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា ។

- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ចាម លេខ ៣៩១ អ.យ.ក.ប.ប.មត ចុះថ្ងៃទី ០៥ ធ្នូ ឆ្នាំ ១៩៩៥ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកំពង់ចាមប្តូរឈ្មោះ សាលាបឋមសិក្សាខ្នារ នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្ត កំពង់ចាម មកជា សាលាបឋមសិក្សា ស ខេង ខ្នារ ចាប់ពីឆ្នាំសិក្សា ១៩៩៥-១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : មន្ទីរក្រសួងអប់រំយុវជន និង កីឡា នាយកដ្ឋានចាត់តាំងនាយកដ្ឋានផែនការ ហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម ការិយាល័យអប់រំយុវជន និង កីឡា ស្រុកត្បូងឃ្មុំ សាលាបឋមសិក្សា ស ខេង ខ្នារ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

តា សាហាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៧៨ អយក.ប្រក
ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃការប្រលង
សញ្ញាបត្រ មធ្យមសិក្សាកម្រិត ១

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ នសរកត ចុះថ្ងៃទី៣១ ខែ ១០ ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ។
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២២៣៧ សជណ. អវ ចុះថ្ងៃទី ១៩-១១- ៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ ។
- បានឃើញប្រកាសក្រសួងលេខ ២៣២៩ ចុះថ្ងៃទី ១៧ .៥.៨០ ស្តីពីការ បង្កើតអោយមាន ការប្រលងសញ្ញាប័ត្រកំរិតសិក្សាទី ២ ។
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និង កីឡា ។

សម្រេច

ប្រការ ១ : មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ លើកទី ១ និង លើកទី ២ ត្រូវ កំណត់ ដោយក្រសួងអប់រំ យុវជន និង កីឡា ជារៀងរាល់ឆ្នាំសិក្សា ។

ប្រការ ២ : ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្ត – ក្រុង និង នាយកគ្រឹះស្ថានសិក្សា ដែលគ្រឹះស្ថាន ត្រូវបានកំណត់ជាមណ្ឌលប្រលងមានភារៈ រៀបចំបន្ទប់ប្រ លង សៀវភៅរូបថតបេក្ខជន បញ្ជីផ្សេង ៗ និងសំភារៈចាំបាច់សំរាប់ការ ប្រព្រឹត្តិទៅ នៃការប្រលង អោយហើយស្រេចមុន បើកសម័យប្រលង ។

- ចំពោះសាលាក្រោមឱវាទផ្ទាល់ នៃក្រសួងអប់រំយុវជន និង កីឡា នាយក គ្រឹះស្ថានសិក្សាក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់ នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យ សិក្សា ។

ប្រការ ៣ : នឹងអាចចុះឈ្មោះប្រលងលើកទី ១ បាន បេក្ខជនទាំងឡាយណាជាសិស្សថ្នាក់ទី ៨ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និង ឯកជនដែលបានរៀនចំកម្មវិធីសិក្សាថ្នាក់ទី ៨ ។ ពាក្យសុំចុះឈ្មោះប្រលងមានបិទតែមត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តាមឋានានុក្រម ។

ប្រការ ៤ : នឹងអាចអនុញ្ញាតអោយចូលរួមប្រលងលើកទី ២ បាន ÷

- បេក្ខជនដែលប្រលងធ្លាក់លើកទី ១ និងបានពិន្ទុសរុប នៃការប្រលងលើកទី ១ចាប់ពី ៣ / ៥ នៃពិន្ទុ ៣០ (គឺចាប់ពីពិន្ទុ ១៨) ឡើងទៅ ។
- បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី ១ តែអាក់ខានពុំបានចូលរួមប្រលង ឬបានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមានជំងឺ ឬគ្រោះថ្នាក់ផ្សេង ។ ជាក់ស្តែង ហើយមានពាក្យសុំច្បាប់ត្រឹមត្រូវ ដោយមានការបញ្ជាក់ពីឪពុកម្តាយ ឬអាណាព្យាបាលស្នើសុំទៅរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា តាមរយៈប្រធានមណ្ឌល ដែលសាម៉ីខ្លួនត្រូវប្រលង ។

ប្រការ ៥ : អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ជាបេក្ខជនស្វ័យរិនបាន អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ។

ប្រការ ៦ : បេក្ខជនត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ ÷

- សលាកប័ត្រឯកត្តជនទំហំ១៥ ស.ម គុណនឹង ២១ ស.ម មានបិទរូបថតថ្មី ថតចំពីមុខទំហំ (៤ ស.ម គុណ ៦ ស.ម) ចំនួន ៤ សន្លឹក ។
- រូបថត ថតថ្មី ថតចំពីមុខ (ទំហំ ៤ ស.ម គុណ ៦ ស.ម) « រូបដែលបានបិទលើសលាកប័ត្រឯកត្តជន »ចំនួន ៣ សន្លឹក ។
- បង្កាន់ដៃបង់សិទ្ធិប្រលងចំនួន ១ ច្បាប់

ប្រការ ៧ : ពាក្យសុំចុះឈ្មោះប្រលងលើកទី ១ និង លើកទី ២ នឹង ត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែលសាមីបេក្ខជនសិក្សា ។ នាយកគ្រឹះស្ថានសិក្សា ត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរអប់រំយុវជន និង កីឡា ខេត្ត

ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរ ទៅតាមមណ្ឌល និងបន្ទប់ប្រលង ។

ប្រការ ៨ : បេក្ខជនដែលបានប្រកាសថាត្រូវបានប្រលងលើកទី ២ មិនបាច់ដាក់ពាក្យសុំប្រលងទៀតទេ ។ មន្ទីរអប់រំយុវជន និង កីឡាខេត្ត–ក្រុងមានភារៈរៀបចំបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរទៅតាមមណ្ឌល និងបន្ទប់ប្រលង។

ប្រការ ៩ : បេក្ខជនស្វ័យរិនត្រូវដាក់ពាក្យសុំប្រលងដោយបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ ដែលបានប្រលងធ្លាក់ពីឆ្នាំមុននៅតាមមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានសុំប្រលងពីឆ្នាំមុន ។ បើមានបំណងចង់ប្រលងនៅខេត្ត–ក្រុងថ្មី ដែលខ្លួនបានប្តូរលំនៅដ្ឋាននោះត្រូវមានសេចក្តីបញ្ជាក់លើពាក្យសុំប្រលងពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង ដែលមានសាមីខ្លួនចនប្រលងធ្លាក់ពីឆ្នាំមុន ។

ប្រការ ១០ : មន្ទីរអប់រំយុវជន និង កីឡា ខេត្ត–ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា «នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា» ដើម្បីពិនិត្យ និង សំរេចលើបេក្ខភាព ។

ប្រការ ១១ : ការក្លែងបន្លំផ្សេងៗ ដោយបេក្ខជន ត្រូវទទួលការបញ្ឈប់មិនអនុញ្ញាតអោយប្រលងចំនួន ពីរឆ្នាំ ។

ប្រការ ១២ : មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និង សមាជិកគណៈមេប្រយោគ មួយចំនួន តាមការចាំបាច់នៃមណ្ឌលប្រលង ។

ប្រការ ១៣ : សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមនៃគណៈមេប្រយោគត្រូវសំរេចដោយ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡាតាម សំណើរបស់ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

ប្រការ ១៤ : ចំនួនអនុរក្ស នៃមណ្ឌលប្រលង ត្រូវគិតតាមចំនួនបន្ទប់ប្រលង គុណនឹង ២,៥ ។

ប្រការ ១៥ : បន្ទប់ប្រលងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម ២៥ «ម្ភៃប្រាំ» នាក់ ។ បើមានបេក្ខជននៅសល់ពី ០៥ «ប្រាំ» នាក់ ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

ប្រការ ១៦ : ប្រធានគណៈមេប្រយោគនៃមណ្ឌលប្រលងនីមួយៗ ជាអ្នកទទួលខុសត្រូវរួមចំពោះមុខក្រសួងអប់រំយុវជន និងកីឡា ក្នុងដំណើរការប្រព្រឹត្តិទៅនៃការប្រឡង ទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសនៃមណ្ឌលប្រលង ។

ប្រការ ១៧ : ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬធ្វើអន្តរាគមដល់អាជ្ញាធរមានសមត្ថកិច្ចនានា ដែលស្ថិតនៅជិតមណ្ឌលប្រលងក្នុងករណីចាំបាច់ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

ប្រការ ១៨ : មណ្ឌល ឬអនុមណ្ឌលប្រឡងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខ-ការណ៍នៃការប្រលង ប្រធានគណៈមេប្រយោគនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេប្រយោគ ទូទាំងប្រទេស ដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំយុវជន និង កីឡា ។

ប្រការ ១៩ : ប្រធានគណៈមេប្រយោគត្រូវ បែងចែកភារកិច្ចដល់អនុប្រធាន និង សមាជិកគណៈមេប្រយោគ អោយទទួលខុសត្រូវតាមមុខងាររៀង ៗ ខ្លួន ។

ប្រការ ២០ : ភារកិច្ចនៃគណៈកម្មការ អនុគណៈកម្មការ និងសមាជិកគណៈកម្មការផ្សេងៗនឹងមានចែងក្នុង សេចក្តីណែនាំមួយរបស់ក្រសួងអប់រំយុវជន និង កីឡា ។

ប្រការ ២១ : នៅពេលប្រលងបេក្ខជនទាំងឡាយ ត្រូវមកប្រលងអោយទាន់ពេលកំណត់ ។ ការមកប្រលងយឺតយ៉ាវលើសពី ១៥ នាទីមិនអនុញ្ញាតអោយចូលប្រឡងឡើយ ។ នៅពេលចូលប្រឡងបេក្ខជន ត្រូវមានលិខិតសំគាល់ខ្លួនដោយមានបិទរូបថត និងមានបញ្ជាក់ច្បាស់លាស់ ។ បេក្ខជនដែលគ្មានលិខិតសំគាល់ខ្លួនមិនអនុញ្ញាតអោយចូលប្រលងឡើយ។

ប្រការ ២២ : មិនអនុញ្ញាតអោយមានការប្រលងជំនួសគ្នាឡើយ ។

ប្រការ ២៣ : មិនអនុញ្ញាតអោយបេក្ខជនទាំងឡាយយកឯកសារនានាជាប់នឹងខ្លួនចូលក្នុងបន្ទប់ប្រឡងជាដាច់ខាត ។

ប្រការ ២៤ : បេក្ខជនទាំងឡាយត្រូវអង្គុយតាមលេខតុ របស់ខ្លួននៅគ្រប់ពេលធ្វើវិញ្ញាសា។

ប្រការ ២៥ : បេក្ខជនទាំងឡាយ ត្រូវធ្វើវិញ្ញាសាលើក្រដាសប្រលង ដែលអនុរក្សចែកអោយ ។ បេក្ខជនមិនត្រូវធ្វើសញ្ញាអ្វីលើក្រដាសប្រលងដែលនាំអោយស្គាល់ថាជាសន្លឹកកិច្ចការរបស់សាម៉ីខ្លួន ជាដាច់ខាត ។ សន្លឹកកិច្ចការប្រលងណាដែលមានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ ។

ប្រការ ២៦ : នៅពេលធ្វើវិញ្ញាសាប្រឡង មិនអនុញ្ញាតអោយបេក្ខជនលួចចម្លង ឬមានបំណងលួចចម្លងជាដាច់ខាត ។ កំហុសនៃការលួចចម្លង ឬបំណងលួចចម្លងនឹងមានចែងក្នុង អត្ថបទ មួយ ។

ប្រការ ២៧ : វិញ្ញាសា និងថេរវេលានៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិ១ លើកទី១ និង លើកទី២ ត្រូវកំណត់ដូចតទៅ ÷

១-តែងសេចក្តី	រយៈពេល	២ ម៉ោង
២-គណិតវិទ្យា	រយៈពេល	២ ម៉ោង
៣-សរសេរតាមអាន និងសំនួរ (សំនួររយៈពេល ៤៥ នាទី ក្រោយពីសរសេរតាមអានចប់)។		
៤-រូបវិទ្យា	រយៈពេល	១ ម៉ោង
៥-គីមី	រយៈពេល	១ ម៉ោង
៦-សីលធម៌-ពលរដ្ឋវិជ្ជា	រយៈពេល	១ ម៉ោង
៧-ជីវវិទ្យា	រយៈពេល	១ ម៉ោង
៨-ភូមិវិទ្យា	រយៈពេល	១ ម៉ោង
៩-ប្រវត្តិវិទ្យា	រយៈពេល	១ ម៉ោង
១០-ជីវភាសា(បារាំង ឬអង់គ្លេស)	រយៈពេល	១ ម៉ោង

ថេរវេលានៃការប្រព្រឹត្តិទៅនៃវិញ្ញាសា ត្រូវគិតចាប់ពីពេលចំលងប្រធានវិញ្ញាសា ឬចែកប្រធាន វិញ្ញាសាអោយបេក្ខជនចប់ ។

ប្រការ ២៨ : ប្រធានវិញ្ញាសាប្រលង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី ៨ នៃមធ្យមសិក្សាកំរិត១ ។ វិញ្ញាសា ទាំងអស់ជាវិញ្ញាសាសរសេរ ។

ប្រការ ២៩ : ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬតាក់តែងដោយក្រសួង អប់រំ យុវជន និងកីឡា ។

ប្រការ ៣០ : ប្រធានវិញ្ញាសាទាំងឡាយដែលជ្រើសរើស ឬតាក់តែងរួចហើយ ត្រូវដាក់ក្នុងស្រោមសំងាត់បិទជិត និងប្រថាប់ត្រាហើយបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតមណ្ឌលប្រលងអោយថែរក្សាទុក ៤៨ ម៉ោងមុនពេលប្រកាសចាប់ផ្តើមប្រលង ។

ប្រការ ៣១ : អាជ្ញាធរមានសមត្ថកិច្ចដែលថែរក្សាប្រធានវិញ្ញាសាទាំងនោះ ត្រូវប្រគល់អោយប្រធានគណៈមេប្រយោគចំពោះមុខសមាជិក នៅថ្ងៃចាប់ផ្តើមការប្រលងមួយម៉ោងមុនពេលបើកសម័យប្រលង ។

ប្រការ ៣២ : ការប្រគល់អោយ និង ការទទួលយកវិញនូវប្រធានវិញ្ញាសាប្រលង ត្រូវមានការទទួលខុស ត្រូវទាំងសងខាងដោយមានកំណត់ហេតុជាផ្លូវការផង ។

ប្រការ ៣៣ : ប្រធានវិញ្ញាសានីមួយៗត្រូវមានចំនួនស្មើនឹងចំនួនបន្ទប់ប្រលង ។ បើខ្វះត្រូវចំលងបន្ថែមបង្គ្រាប់ភ្លាម លើកលែងតែប្រធានវិញ្ញាសាជីវភាសាដែលមានចំនួនស្មើនឹងចំនួនបេក្ខជន ។

ប្រការ ៣៤ : វិញ្ញាសានីមួយៗ ពុំមានមេគុណទេ ហើយត្រូវកំណត់ពិន្ទុដូចតទៅ ÷

១–តែងសេចក្តី	ត្រូវបានពិន្ទុពី	0 ដល់ ១0
២–គណិតវិទ្យា	ត្រូវបានពិន្ទុពី	0 ដល់ ១0
៣–សរសេរតាមអាន និងសំនួរ	ត្រូវបានពិន្ទុពី	0 ដល់ ១0
៤–រូបវិទ្យា	ត្រូវបានពិន្ទុពី	0 ដល់ ៥
៥–គីមី	ត្រូវបានពិន្ទុពី	0 ដល់ ៥
៦–សីលធម៌–ពលរដ្ឋវិជ្ជា	ត្រូវបានពិន្ទុពី	0 ដល់ ៥
៧–ជីវវិទ្យា	ត្រូវបានពិន្ទុពី	0 ដល់ ៥
៨–ភូមិវិទ្យា	ត្រូវបានពិន្ទុពី	0 ដល់ ៥

៩–ប្រវត្តិវិទ្យា ត្រូវបានពិន្ទុពី ០ ដល់ ៥

១០–ជីវភាសា(បារាំងឬអង់គ្លេស)ត្រូវបានពិន្ទុពី ០ ដល់ ៥

វិញ្ញាសានីមួយៗ នឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬបេក្ខជនដែលមិនបានប្រគល់ វិញ្ញាសាដល់គណៈមេប្រយោគ ។

ប្រការ ៣៥ : បេក្ខជនទាំងឡាយ អាចជ្រើសរើសយកភាសាតែមួយប៉ុណ្ណោះ ក្នុងចំណោមភាសាបារាំង ឬភាសាអង់គ្លេសនៅពេលធ្វើវិញ្ញាសាជីវភាសា ។

ប្រការ ៣៦ : ពិន្ទុជីវភាសានឹងគិតយកតែពិន្ទុដែលបេក្ខជនធ្វើបានលើសពី ២,៥០ ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេង ៗ ទៀត ។

ឧទាហរណ៍ :

១-បើបេក្ខជនណាម្នាក់ធ្វើវិញ្ញាសាភាសាបារាំង ឬភាសាអង់គ្លេសបាន ៤ ពិន្ទុ បេក្ខជននោះនឹងត្រូវបាន ១,៥០ ពិន្ទុសំរាប់បូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេងៗទៀត ។

២-បើបេក្ខជនណាម្នាក់ធ្វើវិញ្ញាសាភាសាបារាំង ឬភាសាអង់គ្លេសបានពិន្ទុចាប់ ពី ២,៥០ ចុះ បេក្ខជននោះត្រូវចាត់ទុកថាបានពិន្ទុសូន្យ ចំពោះវិញ្ញាសាជីវភាសា ។

ប្រការ ៣៧ : វិញ្ញាសាសរសេរតាមអានត្រូវគិតជាពីរផ្នែកគឺ ពិន្ទុសរសេរតាមអាន ៥ ពិន្ទុ ពិន្ទុសំណួរ ៥ ពិន្ទុ។ សំនួរសរសេរតាមអានត្រូវអានអោយបេក្ខជនសរសេរ គឺមិន ត្រូវសរសេរនៅលើក្តារខៀនឡើយ ។

ប្រការ ៣៨ : «ពាក្យ »សរសេរខុសនៅក្នុងសរសេរតាមអានត្រូវយកកំហុសតាមតារាងអត្រាកំណែដែលគណៈមេប្រយោគបានសំរេច ។

ប្រការ ៣៩ : វិញ្ញាសាសរសេរនីមួយៗ ត្រូវកែដោយសមាជិកកំណែពីរនាក់ជាដាច់ខាតតាមអត្រាកំណែដែលគណៈមេប្រយោគបានសំរេច ។

ប្រការ ៤០ : នឹងត្រូវប្រកាសថាប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ បេក្ខជនទាំងឡាយណាដែលបានពិន្ទុសរុបចាប់ពី ៣០ ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយលើក លែងតែវិញ្ញាសាជីវភាសា ។ ក្នុងករណីចាំបាច់

គណៈមេប្រយោគអាចធ្វើសំរង់អោយជាប់បន្ថែម ក្រោយពីមានការយល់ព្រមពីក្រសួងអប់រំយុវជន និងកីឡា និងតាមសំណើរបស់គណៈមេប្រយោគហើយត្រូវមានកំណត់ហេតុបញ្ជាក់ច្បាស់លាស់ពីសំរង់បន្ថែម ។ បេក្ខជនស្វ័យរិនមិនធ្វើសំរង់អោយជាប់បន្ថែមឡើយ ។

ប្រការ ៤១ : គណៈមេប្រយោគមណ្ឌលប្រលងនីមួយ ៗ ត្រូវប្រជុំពិភាក្សារួមដើម្បីសំរេចលទ្ធផលនៃការប្រលង ។ កំណត់ហេតុ និងបញ្ជីចាត់ថ្នាក់នានាភ្ជាប់មកជាមួយត្រូវបញ្ជូនទៅក្រសួងអប់រំយុវជន និង កីឡា (នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា) ជាពីរ ច្បាប់ ដើម្បីសុំសេចក្តីយល់ព្រម ។

ប្រការ ៤២ : និទ្ទេសដែលត្រូវកំណត់មានដូចតទៅ ÷

ចាប់ពីពិន្ទុសរុប	៣០,០០	ទៅពិន្ទុសរុប	៣៨,៧៥	និទ្ទេសមធ្យម
ចាប់ពីពិន្ទុសរុប	៣៩,០០	ទៅពិន្ទុសរុប	៤៧,៧៥	និទ្ទេសល្អបង្គួរ
ចាប់ពីពិន្ទុសរុប	៤៨,០០	ឡើងទៅ		និទ្ទេសល្អ

ប្រការ ៤៣ : នឹងត្រូវប្រកាសថាត្រូវបានប្រលងលើកទី ២ បេក្ខជនទាំងឡាយណាដែលមិនបានប្រកាស ថាប្រលងជាប់លើកទី ១ ហើយបានពិន្ទុសរុបចាប់ពី ១៨ ឡើងទៅដោយមិនគិតពិន្ទុសូន្យចំពោះ មុខវិជ្ជាណាមួយ ។

ប្រការ ៤៤ : បទបញ្ញត្តិ ស្តីពីការរៀបចំប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត ១ ពីមុន ៗ ទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៤៥ : ប្រធានមន្ទីរ និងប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា និង អង្គភាពពាក់ព័ន្ធនៃ ក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន ដើម្បីអោយបានសំរេចនូវប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តូច ឡោះ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ២១៩ កទច ប្រក

ស្តីពីការចេញច្បាប់អនុញ្ញាតប្រកបអាជីវកម្ម

សណ្ឋាគារ ផ្ទះសំណាក់

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនៃព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានទេសចរណ៍
- តាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍

សំរេច

មាត្រា ១ : ការអនុញ្ញាតអោយប្រកបអាជីវកម្ម សណ្ឋាគារ ផ្ទះសំណាក់ ត្រូវសំរេចដោយក្រសួង ទេសចរណ៍ មន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

មាត្រា ២ : ការរៀបចំសុំច្បាប់អនុញ្ញាត ឬ ការសុំបន្តអាជីវកម្ម ត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រង ឬ អ្នកចាត់ចែងការងារ សណ្ឋាគារ ផ្ទះសំណាក់ និង ត្រូវធ្វើទៅតាមបែបបទដែលបានកំណត់ និង ភ្ជាប់មកជាមួយនូវឯកសារចាំបាច់ដូចខាងក្រោមនេះ ÷

ក- ការយល់ព្រមលើប្លង់បច្ចុប្បន្ន ពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឬពីអនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ខេត្ត-ក្រុង ។

ខ- ការយល់ព្រមលើសំណង់បច្ចុប្បន្ន ពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ឬ ពីអនុគណៈកម្មាធិការរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ខេត្ត-ក្រុង ។

គ- ការយល់ព្រមលើប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ ដែលចេញដោយក្រសួង មហាផ្ទៃ ។

ឃ- វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

ង- ការយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់ បើសិនអ្នកគ្រប់គ្រង ឬអ្នកចាត់ចែង ការងារមិនមែនជាម្ចាស់កម្មសិទ្ធិ ។

ច- ពត៌មានផ្សេងៗទៀតដែលក្រសួងទេសចរណ៍ត្រូវការ ។

មាត្រា ៣ : អាជីវករត្រូវតែគោរពតាមល័ក្ខខ័ណ្ឌខាងក្រោមអោយបានគ្រប់ពេលវេលា ÷

ក- ត្រូវតែអនុវត្តតាមច្បាប់ និង បទបញ្ញត្តិស្ដីអំពីគំរោងសំណង់ សុវត្ថិភាព អគ្គីភ័យ សុខភាព ម្ហូបអាហារ អនាម័យ ច្បាប់ការងារ ពន្ធដារ និង បទបញ្ញត្តិផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មលើសណ្ឋាគារ ផ្ទះសំណាក់ ។

ខ- ត្រូវផ្ដល់ដំណឹងជាលាយល័ក្ខអក្សរ ជូនក្រសួងទេសចរណ៍នូវការផ្លាស់ប្ដូរ ឈ្មោះចំនួនបន្ទប់ ម្ចាស់ អ្នកគ្រប់គ្រង ឬអ្នកចាត់ចែងការងារ លេខទូរស័ព្ទ ទូរសាររបស់សណ្ឋាគារ ផ្ទះសំណាក់ ។

គ- បុគ្គលិកបំរើការងារត្រូវមានឯកសណ្ឋានសមរម្យ មានអាកប្បកិរិយាថ្លៃថ្នូរ មានសុជីវធម៌ គោរពផលប្រយោជន៍របស់ភ្ញៀវ ។

ឃ- ត្រូវផ្ដល់ជូនក្រសួងទេសចរណ៍ តាមការស្នើសុំនូវពត៌មានលំអិតអំពីការស្នាក់នៅ ថ្លៃបន្ទប់ និង រយៈពេលនៃការស្នាក់នៅ ព្រមទាំងស្ថិតិចំនួន សមត្ថភាពជំនាញ បទពិសោធន៍ របស់បុគ្គលិកដែលបំពេញការងារ ពត៌មានផ្សេងៗដែលក្រសួង ទេសចរណ៍ត្រូវការ ។

ង- ត្រូវតាំងលិខិតអនុញ្ញាត និងបិទថ្លៃបន្ទប់នៅកន្លែងទទួលភ្ញៀវនៃសណ្ឋាគារ ផ្ទះសំណាក់ ។

មាត្រា ៤ : លិខិតអនុញ្ញាតត្រូវមានសុពលភាពសំរាប់រយៈពេលមួយឆ្នាំ ហើយអាច

ដំណើរការបន្តទៀតបាន បើគ្មានយោបល់ជំទាស់ជាលាយលក្ខអក្សរពីក្រសួងទេសចរណ៍ ។ ពេលមានការផ្ទេរ ឬ លក់ អាជីវករត្រូវដាក់ពាក្យសុំទៅក្រសួងទេសចរណ៍តាមទម្រង់បែបបទដែលបានកំណត់ ។ មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតអាជីវករត្រូវដាក់ពាក្យអោយបានមុន មិនលើសពី ២ ខែ និង មិនតិចជាង ១ ខែ ។

មាត្រា ៥ : ក្នុងករណីដែលអាជីវករបានផ្ដល់ពត៌មានមិនពិត ឬ ប្រឌិតពត៌មានពាក់ព័ន្ធក្នុងការដាក់ពាក្យសុំ ឬ មិនបានអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងនៅមាត្រា ៣ ខេ ក្រសួងទេសចរណ៍ នឹងផ្អាក ឬ មិនចេញលិខិតអនុញ្ញាត ដោយផ្ដល់ដំណឹងជាលាយល័ក្ខអក្សររយៈពេល ៣០ ថ្ងៃមុន ។

មាត្រា ៦ : ក្រសួងទេសចរណ៍ នឹងចុះធ្វើអធិការកិច្ចតាមមូលដ្ឋានអាជីវកម្មទាំងអស់ក្នុងពេលវេលា ណាមួយដែលសមស្រប ។ មន្ត្រី រាជការនៃក្រសួងទេសចរណ៍ដែលចុះបំពេញការងារនេះ ត្រូវមានកិច្ចសហការពីមន្ត្រីរាជការនៃក្រសួងសាធារណការ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ នគរបាល ឬមន្ត្រីរាជការខេត្ត–ក្រុង ។

មាត្រា ៧ : ប្រាក់បង់ប្រចាំឆ្នាំក្នុងការចេញប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម ត្រូវកំណត់ដូចក្រោមនេះ ÷

ក–សណ្ឋាគារ :

ក្រោម ៣០ បន្ទប់	៦២៥.០០០៛ ឬ $ ២៥០
ពី ៣១ ដល់ ៧០ បន្ទប់	១ ០០០ ០០០៛ ឬ $ ៤០០
ពី ៧១ ដល់ ១០០ បន្ទប់	១ ២៥០ ០០០៛ ឬ $ ៥០០
ពី ១០១ ដល់ ១៥០ បន្ទប់	១ ៨៧៥ ០០០៛ ឬ $ ៧៥០
ពី ១៥១ ឡើងទៅ	២ ៥០០ ០០០៛ ឬ $ ១ ០០០

ខ–ផ្ទះសំណាក់ : ១២៥ ០០០៛ ឬ $ ៥០

គ–ការផ្ទេរប័ណ្ណអនុញ្ញាតបន្តសកម្មភាពត្រូវគិត ១០ % នៃចំនួនទឹកប្រាក់ដែលបានកំណត់ ក្នុងចំណុច ក ខ និង គ ។

មាត្រា ៨ : ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីអាជីវករបានផ្តល់នូវសំណុំឯកសារគ្រប់គ្រាន់ត្រឹមត្រូវក្នុង ការដាក់ពាក្យសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម តាមការកំណត់របស់ក្រសួងទេសចរណ៍ហើយ អាជីវករអាចអញ្ជើញមកទទួលប័ណ្ណអនុញ្ញាតតាមការកំណត់ ដែលមានចុះលើបង្កាន់ដៃ ទទួលពាក្យ ។

មាត្រា ៩ : ក្នុងរយៈពេលបីខែបន្ទាប់ពីមានការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍ នឹងមិន អនុញ្ញាតអោយមានការធ្វើអាជីវកម្មចំពោះសណ្ឋាគារ ផ្ទះសំណាក់ដែលគ្មានច្បាប់អនុញ្ញាត ទាន់ពេលវេលាទេ ។

មាត្រា ១០ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជាមោឃៈ ។

មាត្រា ១១ : ប្រកាសនេះ មានអានុភាពអនុវត្តន៍ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ២២០ កសច ប្រក
ស្តីពីការចេញច្បាប់អនុញ្ញាតប្រកបអាជីវកម្ម ភោជនីយដ្ឋាន ខ្ទមសាល ឧិស្ថានែក ភាពីរត្បាល
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនៃព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានទេសចរណ៍
- តាមនាយកដ្ឋានឧស្សាហកម្មទេសចរណ៍

សម្រេច

មាត្រា ១ : ការអនុញ្ញាតអោយប្រកបអាជីវកម្ម ភោជនីយដ្ឋាន រង្គសាល ឌីស្កូតែក និង ការ៉ាអូខេ ត្រូវសំរេចដោយក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ខេត្ត-ក្រុង ។

មាត្រា ២ : ការរៀបចំសុំច្បាប់អនុញ្ញាត ឬ ការសុំបន្តអាជីវកម្ម ត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រង ឬអ្នកចាត់ចែងការងារ ភោជនីយដ្ឋាន រង្គសាល ឌីស្កូតែក និង ការ៉ាអូខេ និង ត្រូវធ្វើទៅតាមបែបបទដែលបានកំណត់ និង ភ្ជាប់មកជាមួយនូវឯកសារចាំបាច់ ÷

ក- ការយល់ព្រមលើប្លង់បច្ចុប្បន្ន ពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឬ ពីអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ខេត្ត-ក្រុង ។

ខ- ការយល់ព្រមលើសំណង់បច្ចុប្បន្ន ពីគណកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ឬ ពីអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ខេត្ត-ក្រុង ។

គ- ការយល់ព្រមលើប្រព័ន្ធគ្រប់គ្រងអគ្គិភ័យ ដែលចេញដោយក្រសួងមហាផ្ទៃ

ឃ- ការយល់ព្រមលើអនាម័យ ដែលចេញដោយមន្ទីរសុខាភិបាល រាជធានី ឬ ខេត្ត-ក្រុង ។

ង- វិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

ច- ការយល់ព្រមជាលាយលក្ខអក្សររបស់ម្ចាស់ បើសិនអ្នកគ្រប់គ្រង ឬ អ្នកចាត់ចែងការងារមិនមែនជាម្ចាស់គ្រឹះស្ថាន ។

ឆ- ពត៌មានផ្សេងៗទៀតដែលក្រសួងទេសចរណ៍ត្រូវការ ។

មាត្រា ៣ : ក្រោយពីបានលិខិតអនុញ្ញាតប្រកបអាជីវកម្ម អាជីវករត្រូវតែគោរពតាមល័ក្ខខ័ណ្ឌខាងក្រោម អោយបានគ្រប់ពេលវេលា ÷

ក- ត្រូវតែអនុវត្តតាមច្បាប់ និង បទបញ្ញត្តិស្តីអំពីគំរោងសំណង់ ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យ សុខភាព ម្ហូបអាហារ អនាម័យ ច្បាប់ការងារ ពន្ធដារ ព្រមទាំងច្បាប់ និង បទ បញ្ញត្តិ ផ្សេងៗ ទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍ ។

១– ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ជូនក្រសួងទេសចរណ៍នូវការផ្លាស់ប្តូរ ឈ្មោះ ចំណុះម្ចាស់អ្នកគ្រប់គ្រង ឬ អ្នកចាត់ចែងការងារ លេខទូរស័ព្ទ ឬទូរសារ របស់សេវាកម្មទេសចរណ៍ ។

គ– ត្រូវតែធានាថា ÷

១– អាគារ គ្រឿងតុបតែងលំអ និង សំភារៈផ្សេងៗ និងត្រូវថែរក្សាក្នុងលក្ខណៈ ស្អាតមានរបៀបរៀបរយ និង ប្រកបដោយអនាម័យ ។

២– បុគ្គលិកបំរើការងារ ត្រូវមានឯកសណ្ឋានសមរម្យ មានអាកប្បកិរិយា ថ្លៃថ្នូរ មានសុជីវធម៌ គោរពផលប្រយោជន៍របស់ភ្ញៀវ ។

៣– បុគ្គលិកបំរើការងារអស់ត្រូវមានវិញ្ញាបនប័ត្រពិនិត្យសុខភាព ។

៤– ម្ហូបអាហារ និង ភេសជ្ជៈទាំងអស់ត្រូវសមស្របសំរាប់ការបរិភោគរបស់ មនុស្ស និងគ្មានការស្មោកគ្រោក មិនក្លែងក្លាយ និងមិនបណ្តាលអោយ មានជំងឺ ។

៥– មិនអនុញ្ញាតអោយបុគ្គលដែលមានអាយុតិចជាង ១៨ ឆ្នាំ ចូលកំសាន្តក្នុង រង្គសាល ឌីស្កូតែក ឬ ការ៉ាអូខេ ឡើយ ។

៦– បញ្ជីរាយមុខម្ហូបទាំងអស់ត្រូវសរសេរជាអក្សរខ្មែរព្រមទាំងបកប្រែជាភាសា បរទេស ណាមួយដែលចាំបាច់ ។

៧– គ្រប់សកម្មភាពទាំងអស់ត្រូវគោរពទំនៀមទំលាប់ ប្រពៃណី និង វប្បធម៌ របស់ប្រជាពលរដ្ឋកម្ពុជា ។

ឃ– ត្រូវផ្តល់ជូនក្រសួងទេសចរណ៍ តាមការស្នើសុំនូវពត៌មានលំអិត ចំណូល ស្ថិតិចំនួន សមត្ថភាពជំនាញ បទពិសោធន៍របស់បុគ្គលិកដែលបំពេញការ ងារ និង ពត៌មានផ្សេងៗដែលក្រសួងទេសចរណ៍ត្រូវការ ។

ង– ត្រូវតាំងលិខិតអនុញ្ញាតនៅកន្លែងទទួលភ្ញៀវ ។

មាត្រា ៤ : លិខិតអនុញ្ញាតត្រូវមានសុពលភាពសំរាប់រយៈពេលមួយឆ្នាំ ហើយអាចដំ ណើរការបន្តទៀតបាន លើកលែងតែមានយោបល់ជំទាស់ជាលាយលក្ខណ៍អក្សរ ពីក្រសួង ទេសចរណ៍ ។ ពេលមានការផ្ទេរ ឬ លក់អាជីវកម្មត្រូវដាក់ពាក្យសុំ ទៅក្រសួង ទេសចរណ៍តាមទម្រង់បែបបទដែលបានកំណត់ ។

មុនពេលផុតកំណត់ នៃ លិខិតអនុញ្ញាតអាជីវករត្រូវដាក់ពាក្យសុំអោយបាន មុនមិនលើសពី ២ ខែ និង មិនតិចជាង ១ ខែ ។

មាត្រា ៥ : ក្នុងករណីដែលអាជីវករបានផ្តល់ពត៌មានមិនពិត ឬ ប្រឌិតពត៌មាន ពាក់ព័ន្ធក្នុងការដាក់ពាក្យសុំ ឬមិនបានអនុវត្តតាមល័ក្ខខ័ណ្ឌ ដែលចែងនៅមាត្រា ៣ ទេ ក្រសួងទេសចរណ៍ នឹងផ្អាក ឬមិនចេញលិខិតអនុញ្ញាតជូនដោយផ្តល់ដំណឹងជាលាយលក្ខ អក្សរដល់អាជីវករ រយៈពេល ៣០ ថ្ងៃមុន ។

មាត្រា ៦ : ក្រសួងទេសចរណ៍ នឹងចុះធ្វើអធិការកិច្ចតាមមូលដ្ឋានអាជីវកម្មទាំងអស់ក្នុងពេលវេលា ណាមួយដែលសមស្រប ។ មន្ត្រី រាជការនៃក្រសួងទេសចរណ៍ ដែលចុះបំពេញការងារនេះ មានកិច្ចសហការពីមន្ត្រីរាជការ នៃក្រសួងសាធារណការ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ នគរបាល ឬមន្ត្រីរាជការខេត្ត-ក្រុង ។

មាត្រា ៧ : ប្រាក់បង់ប្រចាំឆ្នាំក្នុងការចេញប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម ត្រូវកំណត់ដូចក្រោមនេះ ÷

ក-ភោជនីយដ្ឋាន

ប្រណិត :

ចំណុះតិចជាង ១០០ នាក់	៦២៥.០០០៛ ឬ $ ២៥០
ពី ១០១ ដល់ ២០០ នាក់	១ ០០០ ០០០៛ ឬ $ ៤០០
លើសពី ២០០ នាក់	១ ២៥០ ០០០៛ ឬ $ ៥០០

ធម្មតា :

ចំណុះតិចជាង ១០០ នាក់	១២៥ ០០០៛ ឬ $ ៥០
ពី ១០១ ដល់ ២០០ នាក់	២៥០ ០០០៛ ឬ $ ១០០
លើសពី ២០០ នាក់	៣៧៥ ០០០៛ ឬ $ ១៥០

ខ-ឌីស្កូ កាក់អូខេ :

ពី ៤០ ដល់ ១០០ នាក់	៦២៥ ០០០៛ $ ២៥០
លើសពី ១០០ នាក់	៧៥០ ០០០៛ ឬ $ ៣០០

គ-រង្គសាល :

តិចជាង ៨០ នាក់	៦២៥ ០០០៛ ឬ $ ២៥០
ពី ៨១ ដល់ ១៥០ នាក់	៨៧៥ ០០០៛ ឬ $ ៣៥០
ពី ១៥១ ដល់ ២០០ នាក់	១ ៥០០ ០០០៛ ឬ $ ៦០០
លើសពី ២០០ នាក់	១ ៨៧៥ ០០០៛ ឬ $ ៧៥០

ឃ- ថ្លៃផ្ទេរប័ណ្ណអនុញ្ញាតបន្តសកម្មភាពត្រូវគិត ១០ % លើសថ្លៃកំណាណត់ក្នុងការចេញ ប័ណ្ណ ក្នុងចំណុចកំណត់ថ្លៃខាងលើ ។

មាត្រា ៨ : ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីអាជីវករបានផ្តល់នូវសំណុំឯកសារគ្រប់គ្រាន់ត្រឹមត្រូវក្នុងការដាក់ពាក្យសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម តាមការកំណត់របស់ក្រសួងទេសចរណ៍ហើយ អាជីវករអាចអញ្ជើញមកទទួលប័ណ្ណអនុញ្ញាតតាមការកំណត់ដែលមានចុះលើបង្កាន់ដៃទទួលពាក្យ ។

មាត្រា ៩ : ក្នុងរយៈពេលបីខែបន្ទាប់ពីមានការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍ នឹងមិនអនុញ្ញាតអោយមានការធ្វើអាជីវកម្មចំពោះភោជនីយដ្ឋាន វង្គសាល ឌីស្កូតែក កាភ័អូខេ ដែលគ្មានច្បាប់ អនុញ្ញាតទេ ។

មាត្រា ១០ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជាមោឃៈ ។

មាត្រា ១១ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍន៍

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ២២១ ករច ប្រក

ស្តីពីការធ្វើអាជីវកម្មនៅមណ្ឌលដ្ឋានទេសចរណ៍

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនៃព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកទេសចរណ៍
- តាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍

សម្រេច

មាត្រា ១ : ការធ្វើអាជីវកម្មនៅរមណីយដ្ឋានទេសចរណ៍ ត្រូវសំរេចដោយក្រសួងទេសចរណ៍ ។

មាត្រា ២ : ការរៀបចំសុំច្បាប់អនុញ្ញាត ឬ ការសុំបន្តអាជីវកម្មត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រង ឬ អ្នកចាត់ចែងការងាររមណីយដ្ឋានទេសចរណ៍ នឹងត្រូវធ្វើទៅតាមបែបបទដែលបានកំណត់ និងភ្ជាប់មកជាមួយនូវឯកសារចាំបាច់ដូចខាងក្រោមនេះ ៖

ក- ប្លង់រមណីយដ្ឋាន ត្រូវមានការឯកភាពពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ឬ គណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង ។

ខ- ពត៌មានលំអិតស្តីពីការរៀបចំ ដើមទុន របាយការណ៍បច្ចេកទេស សំភារៈដែលនឹងរៀបចំសំរាប់ការកំសាន្តរបស់ភ្ញៀវទេសចរ ចំនួនបន្ទប់ភ្ញៀវ លេងកីឡា ចំនួនសមត្ថភាពជំនាញ បទពិសោធន៍របស់បុគ្គលិកដែលបំពេញការងារ ។

គ- វិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ឃ- ប័ណ្ណធានារ៉ាប់រង

ង- ពត៌មានផ្សេងៗទៀតដែលក្រសួងទេសចរណ៍ត្រូវការ

មាត្រា ៣ : អាជីវករត្រូវតែគោរពតាមល័ក្ខខ័ណ្ឌខាងក្រោមអោយបានគ្រប់ពេលវេលា ៖

ក–អនុវត្តតាមច្បាប់ការងារ ពន្ធដារ បទបញ្ញត្តិផ្សេងៗរបស់អាជ្ញាធរ ខេត្ត ក្រុង ក្រសួងទេសចរណ៍ សារាចរណែនាំស្តីពីការធ្វើអាជីវកម្ម និងច្បាប់ផ្សេងៗ ។

ខ–ផ្តល់ដំណឹងជាលាយលក្ខអក្សរ ជូនក្រសួងទេសចរណ៍នូវការផ្លាស់ប្តូរឈ្មោះអ្នកគ្រប់គ្រង ឬ អ្នកចាត់ចែងការងារ លេខទូរស័ព្ទ ទូរសារ និងស្ថិតិភ្ញៀវប្រចាំ ខែ ...។

គ–ធានាថា គ្រប់សកម្មភាពទាំងអស់មិនប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ បរិស្ថាន សុវត្ថិភាព ទំនៀមទំលាប់ ប្រពៃណី និងវប្បធម៌របស់ប្រជាពលរដ្ឋកម្ពុជា ។

ឃ–តាំងលិខិតអនុញ្ញាតនៅកន្លែងទទួលភ្ញៀវ ។

មាត្រា ៤ : លិខិតអនុញ្ញាតត្រូវមានសុពលភាពសំរាប់រយៈពេលមួយឆ្នាំ ហើយអាចដំណើរការបន្តទៀតបាន លើកលែងតែមានយោបល់ជំទាស់ជាលាយលក្ខអក្សរពីក្រសួងទេសចរណ៍ ។

ពេលមានការផ្ទេរ ឬលក់អាជីវករត្រូវដាក់ពាក្យសុំទៅក្រសួងទេស-ចរណ៍តាមទម្រង់បែបបទ ដែលបានកំណត់ ។

មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតអាជីវករត្រូវដាក់ពាក្យអោយបានមុនមិនលើសពី ខែ២ និងមិនតិចជាង ១ ខែ ។

មាត្រា ៥ : ក្នុងករណីអាជីវករបានផ្តល់ពតិមានមិនពិត ឬ ប្រឌិតពតិមាន ពាក់ព័ន្ធក្នុងការដាក់ពាក្យ សុំ ឬ មិនបានអនុវត្តតាមលក្ខខ័ណ្ឌដែលចែងនៅមាត្រា ៣ ទេ ក្រសួងទេសចរណ៍នឹងផ្អាក ឬ មិន ចេញលិខិតអនុញ្ញាតជូនដោយផ្តល់ជូនដំណឹងជាលាយលក្ខអក្សរដល់អាជីវកររយៈពេល ៣០ ថ្ងៃមុន។

មាត្រា ៦ : ក្រសួងទេសចរណ៍នឹងចុះធ្វើអធិការកិច្ច តាមមូលដ្ឋានអាជីវកម្មទាំងអស់ក្នុងពេលវេលាណាមួយដែលសមស្រប ។

មន្ត្រីរាជការនៃក្រសួងទេសចរណ៍ដែលចុះបំពេញការងារនេះត្រូវមានកិច្ច

សហការពីមន្ត្រីរាជការនៃក្រសួងសាធារណការ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ នគរបាល ឬ មន្ត្រី រាជការ ខេត្ត - ក្រុង ។

មាត្រា ៧ : ប្រាក់បង់ប្រចាំឆ្នាំក្នុងការចេញប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មត្រូវកំណត់ចំនួន ៦២៥.០០០៛ ឬ US $ ២៥០ ។ ការផ្ទេរប័ណ្ណអនុញ្ញាតបន្តសកម្មភាពត្រូវគិត ១០ % នៃ ចំនួនទឹកប្រាក់ដែលបាន កំណត់ខាងលើ ។

មាត្រា ៨ : ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីអាជីវករបានផ្តល់នូវសំណុំឯកសារគ្រប់គ្រាន់ ត្រឹមត្រូវក្នុង ការដាក់ពាក្យសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម តាមការកំណត់របស់ក្រសួងទេសចរណ៍ហើយអាជីវករ អាចអញ្ជើញមកទទួលប័ណ្ណអនុញ្ញាតតាមការកំណត់ដែលមានចុះលើបង្កាន់ដៃទទួលពាក្យ ។

មាត្រា ៩ : ក្នុងរយៈពេលបីខែ បន្ទាប់ពីមានការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍ នឹង មិនអនុញ្ញាតអោយមានការធ្វើអាជីវកម្មរមណីយដ្ឋានទេសចរណ៍ដែលគ្មានច្បាប់អនុញ្ញាតទាន់ពេលវេលាទេ ។

មាត្រា ១០ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយ នឹងប្រកាសនេះត្រូវទុកជាមោឃៈ ។

មាត្រា ១១ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ២២២ ទសច ប្រក
ស្តីពីការចេញលិខិតអនុញ្ញាតជូនមគ្គុទ្ទេសក៍ទេសចរណ៍

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យនៃព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចុះនៅព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ១៩៩២ ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានទេសចរណ៍
- តាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
- តាមការចាំបាច់របស់ក្រសួងទេសចរណ៍

សម្រេច

មាត្រា ១ : ការអនុញ្ញាតអោយបង្កើតមគ្គុទ្ទេសក៍ មគ្គុទ្ទេសក៍ទេសចរជាតិ មគ្គុទ្ទេសក៍ទេសចរតំបន់ត្រូវសំរេចដោយក្រសួងទេសចរណ៍ ។

មាត្រា ២ : ការរៀបចំសុំច្បាប់អនុញ្ញាត ឬ សុំបន្តសកម្មភាពមគ្គុទ្ទេសក៍ត្រូវមានឯកសារដូចខាងក្រោមនេះ :

ក– សញ្ញាប័ត្រប្រឡងជាប់ជាមគ្គុទ្ទេសក៍ទេសចរ ដែលចេញដោយក្រសួងទេសចរណ៍ ។

ខ– វិញ្ញាបនប័ត្រពិនិត្យសុខភាព កាយសម្បទា សៀវភៅការងារ ។

គ– សំបុត្របញ្ជាក់ទោស ។

ឃ– រូបថតដែលមានទំហំ ៤ × ៦ ចំនួន ៣ សន្លឹក ។

ង– ពត៌មានផ្សេងទៀតដែលក្រសួងទេសចរណ៍ត្រូវការ ។

មាត្រា ៣ : មគ្គុទ្ទេសក៍ត្រូវតែគោរពអនុវត្តនូវកិច្ចការសំខាន់ៗដូចខាងក្រោមនេះ :

ក– ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរ ជូនក្រសួងទេសចរណ៍នូវលិខិតទទួលស្គាល់សមត្ថភាពជំនាញ ការផ្លាស់ប្តូរអាស័យដ្ឋាន លេខទូរស័ព្ទនិងទូរសារ ហើយធ្វើការដោយខ្លួនឯង ឬជាបក្ខកិច្ចសន្យាធ្វើការអោយក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ក្នុងពេលមានការផ្លាស់ប្តូរនិយោជិក ។

ខ– ត្រូវចូលរួមកម្មវិធីបណ្តុះបណ្តាលបន្ថែម ដែលក្រសួងទេសចរណ៍រៀបចំឡើងជាបន្តបន្ទាប់ស្របតាមសេចក្តីត្រូវការ ។

គ-ត្រូវផ្តល់ជូនក្រសួងទេសចរណ៍តាមការស្នើសុំនូវពត៌មានលំអិត អំពីពេលវេលាចំនួន និង សញ្ជាតិរបស់ទេសចរ ឈ្មោះរបស់ទីភ្នាក់ងារទេសចរណ៍ដែលមគ្គុទ្ទេសក៍បំរើការងារអោយជាមគ្គុទ្ទេសក៍ទេសចរ ព្រមទាំងមានពត៌មានលំអិត អំពីតំលៃសេវាកម្មមគ្គុទ្ទេសក៍ទេសចរ ស្ថិតិ និងពត៌មានផ្សេង ៗ ដែលក្រសួងទេសចរណ៍ត្រូវការ ។

ឃ-គ្រប់ពេលបំពេញការងារមគ្គុទ្ទេសក៍ទេសចរ ត្រូវតែ :

១-ប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ មានសុជីវធម៌ គោរពផលប្រយោជន៍របស់ភ្ញៀវ ក៏ដូចជាទំនៀមទំលាប់ប្រពៃណី វប្បធម៌ របស់ប្រជាពលរដ្ឋខ្មែរ ។

២-ស្លៀកពាក់តាមបែបបទនិងគំរូ ដែលបានកំណត់ដោយក្រសួងទេសចរណ៍ ។

៣-ពាក់បណ្ណសំគាល់ ។

មាត្រា ៤ : លិខិតអនុញ្ញាតត្រូវមានសុពលភាពសំរាប់រយៈពេលមួយឆ្នាំ ហើយអាចដំណើរការបន្តទៀត បានលើកលែងតែមានយោបល់ជំទាស់ជាលាយលក្ខអក្សរពីក្រសួងទេសចរណ៍ ។

លិខិតអនុញ្ញាតមិនអាចផ្ទេរ ឬ ប្រើដោយបុគ្គលផ្សេង ក្រៅពីមគ្គុទ្ទេសក៍ជាម្ចាស់បានឡើយ ។ មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតមគ្គុទ្ទេសក៍ត្រូវដាក់ពាក្យសុំបន្តសកម្មភាពអោយបានមុនមិនលើសពី ២ ខែ និងមិនតិចជាង ១ ខែ ។

មាត្រា ៥ : ក្នុងករណីមគ្គុទ្ទេសក៍បានផ្តល់ពត៌មានមិនពិត ឬ ប្រឌិតពត៌មានពាក់ព័ន្ធក្នុងការដាក់ពាក្យសុំ ឬមិនបានអនុវត្តតាមលក្ខខ័ណ្ឌដែលមានចែងនៅមាត្រា ៣ ទេ ក្រសួងទេសចរណ៍ នឹងផ្អាកសកម្មភាព ឬមិនចេញលិខិតអនុញ្ញាតជូន ដោយផ្តល់ដំណឹងជាលាយលក្ខអក្សរដល់មគ្គុទ្ទេសក៍រយៈពេល៣០ ថ្ងៃមុន ។

មាត្រា ៦ : នៅរពេលដែលមគ្គុទ្ទេសក៍ទេសចរ មិនទាន់បានទទួលនូវភាពស្ទាត់ជំនាញផ្នែកភាសាតាម ការតំរូវដោយក្រសួងទេសចរណ៍ទេនោះ ការដាក់ពាក្យសុំអាចធ្វើឡើង បានសំរាប់លិខិតអនុញ្ញាតបណ្តោះអាសន្នប៉ុណ្ណោះ ។

ក្រសួងទេសចរណ៍អាចចេញលិខិតអនុញ្ញាតបណ្ដោះអាសន្ន ដោយស្ថិតនៅក្រោមលក្ខខណ្ឌ ពិសេសដូចតទៅ ៖

ក-អ្នកដាក់ពាក្យសុំត្រូវផ្ដល់ជូនក្រសួងទេសចរណ៍នូវពត៌មានពិស្ដារ អំពីវគ្គសិក្សាដោយមានការបញ្ជាក់ពីស្ថាប័នបណ្ដុះបណ្ដាលភាសា ដែលពាក់ព័ន្ធ ។

ខ-អ្នកដាក់ពាក្យសុំត្រូវបំពេញការសិក្សា ក្នុងរយៈពេលដែលបានកំណត់មួយមិនលើសពី ៦ ខែ តាមការយល់ព្រមពីស្ថាប័នបណ្ដុះបណ្ដាលភាសានោះ ។

គ-នៅពេលបញ្ចប់ការសិក្សាបន្ថែមដោយជោគជ័យហើយ អ្នកដាក់ពាក្យសុំត្រូវផ្ដល់ជូន ក្រសួងទេសចរណ៍នូវសំណៅចំលងវិញ្ញាបនប័ត្ររបស់ស្ថាប័នបណ្ដុះបណ្ដាលភាសា ដើម្បីក្រសួងទេសចរណ៍ទទួលស្គាល់សមត្ថភាពរបស់អ្នកដាក់ពាក្យសុំក្នុងភាសាបរទេសនោះ ។

មាត្រា ៧ : ប្រាក់បង់ប្រចាំឆ្នាំជូនក្រសួងទេសចរណ៍ត្រូវកំណត់ ៧៥.០០០៛ ឬ US $ ៣០ សំរាប់លិខិតអនុញ្ញាត លិខិតអនុញ្ញាតបណ្ដោះអាសន្ន ឬ សុំបន្តសកម្មភាព ។

មាត្រា ៨ : ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីមគ្គុទ្ទេសក៍បានផ្ដល់នូវសំណុំឯកសារគ្រប់គ្រាន់ ត្រឹមត្រូវ ក្នុងការដាក់ពាក្យសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មតាមការកំណត់របស់ក្រសួងទេសចរណ៍ហើយមគ្គុទ្ទេសក៍ អាចអញ្ជើញមកទទួលប័ណ្ណអនុញ្ញាតតាមការកំណត់ ដែលបានចុះលើបង្កាន់ដៃទទួលពាក្យ ។

មាត្រា ៩ : ក្នុងរយៈពេលបីខែ បន្ទាប់ពីមានការចុះហត្ថលេខាលើប្រកាសនេះក្រសួងទេសចរណ៍ នឹងមិនអនុញ្ញាតអោយបុគ្គលណាធ្វើជាមគ្គុទ្ទេសក៍ដោយគ្មានលិខិតអនុញ្ញាតទេ ។

ទីភ្នាក់ងារទេសចរណ៍ អ្នករៀបចំដំណើរកំសាន្ត មិនប្រើប្រាស់ ឬ ផ្ដល់ជូនទេសចរនូវ សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ដែលគ្មានលិខិតអនុញ្ញាតទេ ។

មាត្រា ១០ : ក្រសួងទេសចរណ៍នឹងចុះធ្វើអធិការកិច្ច តាមមូលដ្ឋានអាជីវកម្មទាំងអស់

ក្នុងពេលវេលាណាមួយដែលសមស្រប ។ មន្ត្រីរាជការនៃក្រសួងទេសចរណ៍ ដែលចុះបំពេញការងារនេះ ត្រូវមានកិច្ចសហការពីមន្ត្រីរាជការ នៃក្រសួងសាធារណការ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ នគរបាល ឬ មន្ត្រីរាជការ ខេត្ត - ក្រុង ។

មាត្រា ១១ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជាមោឃៈ ។

មាត្រា ១២ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សិរីវុឌ្ឍ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ២២៣ កទច ប្រក

ស្តីពីការប្រកបអាជីវកម្មដឹកជញ្ជូនទេសចរតាមយានយន្ត

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនៃព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ១៩៩២ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានទេសចរណ៍
- តាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍

សម្រេច

មាត្រា ១ : ការអនុញ្ញាតអោយប្រកបអាជីវកម្មដឹកជញ្ជូនទេសចរតាមយានយន្ត ត្រូវ សំរេចដោយក្រសួងទេសចរណ៍ ។

មាត្រា ២ : ការរៀបចំសុំច្បាប់អនុញ្ញាត ឬ ការសុំបន្តអាជីវកម្មត្រូវធ្វើឡើងដោយអ្នក គ្រប់គ្រង ឬ អ្នក ចាត់ចែងការងារដឹកជញ្ជូនទេសចរតាមយានយន្ត និង ត្រូវធ្វើទៅតាមបែបបទដែលបានកំណត់ និង ភ្ជាប់មកជាមួយនូវឯកសារ ចាំបាច់ដូចខាងក្រោមនេះ ÷

ក-ប័ណ្ណសំគាល់យានយន្ត ដែលចេញដោយក្រសួងសាធារណការ និងដឹក ជញ្ជូន. ។

ខ-លិខិតអនុញ្ញាតរបស់អ្នកបើកបរយានយន្ត ដែលចេញដោយក្រសួង សាធារណការ និង ដឹកជញ្ជូន ។

គ-វិញ្ញាបនប័ត្របញ្ជាក់ពីលក្ខណៈបច្ចេកទេស ។

ឃ-វិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

ង-ការយល់ព្រមជាលាយលក្ខអក្សររបស់ម្ចាស់យានយន្ត បើអាជីវករ មិនមែនជាម្ចាស់ ។

ច-ពត៌មានផ្សេងៗទៀត ដែលក្រសួងទេសចរណ៍ត្រូវការ ។

មាត្រា ៣ : អាជីវករត្រូវតែគោរពតាមលក្ខខ័ណ្ឌខាងក្រោមអោយបានគ្រប់ពេលវេលា ÷

ក-ត្រូវតែអនុវត្តតាមច្បាប់ និងបទបញ្ញត្តិយានយន្ត សុវត្ថិភាព សុខភាព អនាម័យ ច្បាប់ ការងារ ពន្ធដារ ព្រមទាំងច្បាប់និងបទបញ្ញត្តិផ្សេងៗ ទៀតដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មយានយន្ត ។

ខ-ត្រូវផ្តល់ដំណឹងជាលាយលក្ខអក្សរ ជូនក្រសួងទេសចរណ៍នូវការផ្លាស់ ប្តូរនាមករណ៍ អ្នកបើកបរយានយន្ត យន្តការី ចំណុះអ្នកដំណើរ ម្ចាស់ អាជីវករ លេខទូរស័ព្ទ ឬ ទូរសាររបស់ម្ចាស់យានយន្ត ឬ ក្រុមហ៊ុន ។

គ-គ្រប់ពេលវេលាដែលមានការដឹកជញ្ជូនភ្ញៀវទេសចរ ត្រូវធានាថា ÷

១-មិនបើកបរនៅពេលស្រវឹង ។

២-មិនពិសារបារីនៅពេលបើកបរ ។

៣–បុគ្គលិកបំរើការងារនៅលើយានយន្តត្រូវមានឯកសណ្ឋានសមរម្យ មានអាកប្បកិរិយា ថ្លៃថ្នូរ មានសុជីវធម៌ គោរពផលប្រយោជន៍របស់ទេសចរទាំងឡាយទំលាប់ និងប្រពៃណី របស់ប្រជាពលរដ្ឋកម្ពុជា ។

៤–យានយន្តត្រូវតែទទួលការថែទាំហើយអាចប្រើប្រាស់បានដោយសុវត្ថិភាព។

៥–យានយន្តត្រូវមានប្រអប់ថ្នាំសំរាប់សង្គ្រោះ សំភារៈបង្ការនិងពន្លត់អគ្គីភ័យ យានយន្តដែលមានចំណុះពី ២០ នាក់ ឡើងទៅត្រូវមានប្រព័ន្ធបំពងសំលេង ។

៦–ត្រូវសរសេរ ឬបិទផ្លាកសញ្ញាសំគាល់ថាជាយានយន្តដឹកទេសចរ ឈ្មោះទីភ្នាក់ងារ ក្រុមហ៊ុនជាភាសាខ្មែរនិងភាសាបរទេសណាមួយដែលចាំបាច់ ។

ឃ–ត្រូវផ្តល់ជូនក្រសួងទេសចរណ៍តាមការស្នើសុំនូវពត៌មានលំអិតអំពីចំនួនអ្នកដំណើរដែលបានដឹកជញ្ជូន ថ្លៃឈ្នួល ស្ថិតិ ចំនួន សមត្ថភាពជំនាញបទពិសោធន៍របស់បុគ្គលិកដែលបំពេញការងារ ពត៌មានផ្សេងៗដែលក្រសួងទេសចរណ៍ត្រូវការ ។

ង–ត្រូវតាំងលិខិតអនុញ្ញាត និងប័ណ្ណបើកបរនៅកន្លែងបើកបរ ។

មាត្រា ៤ : លិខិតអនុញ្ញាតត្រូវមានសុពលភាពសំរាប់រយៈពេលមួយឆ្នាំ ហើយអាចដំណើរការបន្តទៀត បានលើកលែងតែមានយោបល់ជំទាស់ជាលាយល័ក្ខអក្សរពីក្រ សួងទេសចរណ៍ ។

ពេលមានការផ្ទេរ ឬ លក់អាជីវករត្រូវដាក់ពាក្យសុំទៅក្រសួងទេសចរណ៍តាមទម្រង់បែបបទដែលបានកំណត់ ។

មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតអាជីវករត្រូវដាក់ពាក្យអោយបានមុនលើសពី ២ ខែ និងមិនតិចជាង ១ ខែ ។

មាត្រា ៥ : ក្នុងករណីអាជីវករបានផ្តល់ពត៌មានមិនពិត ឬ ប្រឌិតពត៌មាន ពាក់ព័ន្ធក្នុងការដាក់ពាក្យសុំ ឬមិនបានអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងនៅមាត្រា ៣ ទេ ក្រសួងទេសចរណ៍ និងផ្អាក ឬមិនចេញលិខិតអនុញ្ញាតជូនដោយផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់អាជីវកររយៈពេល ៣០ថ្ងៃមុន ។

មាត្រា ៦ : ក្រសួងទេសចរណ៍នឹងចុះធ្វើអធិការកិច្ច តាមមូលដ្ឋានអាជីវកម្មទាំងអស់ក្នុងពេលវេលាណាមួយដែលសមស្រប ។ មន្ត្រីរាជការនៃក្រសួងទេសចរណ៍ដែលចុះបំពេញការងារនេះត្រូវមានកិច្ចសហការពីមន្ត្រីរាជការ នៃក្រសួងសាធារណការ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ នគរបាល ឬ មន្ត្រីរាជការ ខេត្ត ក្រុង ។

មាត្រា ៧ : ប្រាក់បង់ប្រចាំឆ្នាំក្នុងការចេញប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មត្រូវកំណត់ដូចខាងក្រោមនេះ ÷

ក-យានយន្តដែលមានចំណុះ

អ្នកដំណើរតិចជាង ១២ នាក់ ទៅ ៣០ នាក់ ១២៥.០០០៛ ឬ US $៥០

អ្នកដំណើរពី ១៣ នាក់ ទៅ ៣០ នាក់ ២៥០.០០០៛ ឬ US $ ១០០

អ្នកដំណើរពី ៣១ ឡើងទៅ ៣៧៥.០០០៛ ឬ US $ ១៥០

ខ-ការផ្ទេរប័ណ្ណអនុញ្ញាតបន្តសកម្មភាពត្រូវគិត ១០ % លើប្រាក់ដែលបានកំណត់ក្នុង ចំណុច ក ។

មាត្រា ៨ : ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីអាជីវករបានផ្តល់នូវសំណុំឯកសារគ្រប់គ្រាន់ត្រឹមត្រូវក្នុងការដាក់ពាក្យសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម តាមការកំណត់របស់ក្រសួងទេសចរណ៍ ហើយអាជីវករ អាចអញ្ជើញមកទទួលយកប័ណ្ណអនុញ្ញាតតាមការកំណត់ដែលមានចុះលើបង្កាន់ដៃទទួលពាក្យ ។

មាត្រា ៩ : ក្នុងរយៈពេលបីខែ បន្ទាប់ពីមានការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍ នឹង មិនអនុញ្ញាតអោយមានការធ្វើអាជីវកម្ម ចំពោះយានយន្តដែលគ្មានច្បាប់អនុញ្ញាតទេ ។

មាត្រា ១០ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជាមោឃៈ ។

មាត្រា ១១ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ២២៤ កខប ប្រក

ស្តីពីការចេញច្បាប់អនុញ្ញាតប្រកបអាជីវកម្ម

នាវាដឹកជញ្ជូនទេសចរ

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យនៃព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាល កម្ពុជា

– បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ១៩៩២ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានទេសចរណ៍

– តាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មទេសចរណ៍

សម្រេច

មាត្រា ១ : ការអនុញ្ញាតអោយបង្កើតនាវាដើម្បីរៀបចំដំណើរកំសាន្តតាមផ្លូវទឹកជូន ទេសចរណ៍ ត្រូវសំរេចដោយក្រសួងទេសចរណ៍ ។

មាត្រា ២ : ការរៀបចំសុំច្បាប់អនុញ្ញាត ឬការសុំបន្តអាជីវកម្មត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រង ឬអ្នកចាត់ចែងការងារនាវានឹងត្រូវធ្វើ ទៅតាមបែបបទដែលបានកំណត់ និងភ្ជាប់មកជាមួយនូវឯកសារចាំបាច់ដូច ខាងក្រោមនេះ ÷

ក–ប័ណ្ណសំគាល់នាវាដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន។

ខ–លិខិតអនុញ្ញាតរបស់អ្នកបើកបរនាវា ដែលចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ។

គ–លិខិតអនុញ្ញាតរបស់យន្តការី ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

ឃ–វិញ្ញាបនប័ត្របញ្ជាក់អំពីលក្ខណៈបច្ចេកទេស ។

ង–វិញ្ញាបនប័ត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

ច–ការយល់ព្រមជាលាយល័ក្ខអក្សររបស់ម្ចាស់នាវា បើអាជីវករមិនមែនជាម្ចាស់នាវាទេ ។

ឆ–ពត៌មានផ្សេងៗទៀតដែលក្រសួងទេសចរណ៍ត្រូវការ ។

មាត្រា ៣ : អាជីវករត្រូវតែគោរពតាមល័ក្ខខ័ណ្ឌខាងក្រោមអោយបានគ្រប់ពេលវេលា ÷

ក–ត្រូវតែអនុវត្តតាមច្បាប់និងបទបញ្ញត្តិនាវាចរណ៍ សុវត្ថិភាព សុខភាព ម្ហូបអាហារ អនាម័យ ច្បាប់ការងារ ពន្ធដារ ព្រមទាំងច្បាប់ និងបទបញ្ញត្តិផ្សេង ៗ ទៀតដែលពាក់ព័ន្ធទៅនឹងការធ្វើនាវាចរណ៍ និងការធ្វើអាជីវកម្មលើនាវាទេសចរណ៍ ។

ខ–ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរ ជូនក្រសួងទេសចរណ៍នូវការផ្លាស់ប្តូរនាមករណ៍ អ្នកបើកបរនាវា យន្តការី ចំណុះអ្នកដំណើរ ម្ចាស់អាជីវករ លេខទូរស័ព្ទ ទូរសារ របស់នាវាទេសចរណ៍ និងក្រុមហ៊ុន ។

គ–គ្រប់ពេលដែលទេសចរកំពុងជិះលើនាវា បុគ្គលិកបំរើការងារទាំងអស់ត្រូវធានាថា :

១–មិនបើកបរនៅពេលស្រវឹង ។

២–មិនពិសារបារីនៅពេលបើកបរ ។

៣–បុគ្គលិកបំរើការងារ ត្រូវមានឯកសណ្ឋានសមរម្យ មានអាកប្បកិរិយាថ្លៃថ្នូរមានសុជីវធម៌ គោរពផលប្រយោជន៍របស់ភ្ញៀវទំនៀមទំលាប់ និងប្រពៃណី របស់ប្រជាពលរដ្ឋកម្ពុជា ។

៤–នាវាមិនត្រូវដឹកជញ្ជូនទេសចរលើសពីចំណុះដែលបានអនុញ្ញាត ។

៥–នាវាត្រូវតែទទួលការថែទាំដើម្បីប្រើប្រាស់បានដោយសុវត្ថិភាព ។

៦–នាវាត្រូវផ្ទុកអោយបានគ្រប់គ្រាន់នូវសំភារៈ និងឧបករណ៍បន្ថែមដែលមានក្នុងសារាចរណែនាំ ស្តីពីការងារគ្រប់គ្រងជលយាននិងជលយានយន្ត

គ្រប់ប្រភេទ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៨៩ ។

៧- នាវាត្រូវផ្ទុកអាវ ឬពោងសំរាប់ជួយស្រោចស្រង់ជីវិតមិនអោយតិចជាងចំនួនអ្នកដំណើរ និងនាវិកឡើយ ។

៨- នាវាដែលមានចំណុះអ្នកដំណើរពី ១៥ នាក់ឡើងទៅត្រូវផ្ទុក ឬសណ្តោងទូកសង្គ្រោះមួយ ឬ ច្រើនដែលមានចំណុះគ្រប់គ្រាន់សំរាប់ដឹកនាំអ្នកដំណើរ និង នាវិកមកកាន់ច្រាំងបានដោយសុវត្ថិភាព ។

ឃ- ត្រូវថែរក្សា និងទុកដាក់បញ្ជីអ្នកដំណើរ ហើយត្រូវអនុញ្ញាតអោយមន្ត្រីក្រសួងទេសចរណ៍ត្រួតពិនិត្យបញ្ជីនោះតាមការស្នើសុំ ។

ង- ម្ចាស់លិខិតអនុញ្ញាតត្រូវផ្តល់ជូនក្រសួងទេសចរណ៍ តាមការស្នើសុំនូវពត៌មានលំអិតអំពីចំនួនអ្នកដំណើរដែលបានដឹកនាំថ្លៃឈ្នួល ស្ថិតិ ចំនួនសមត្ថភាពជំនាញ បទពិសោធន៍របស់ បុគ្គលិកដែលបំពេញការងារ ពត៌មានផ្សេងៗដែលក្រសួងទេសចរណ៍ត្រូវការ ។

ច- ត្រូវតាំងលិខិតអនុញ្ញាតក្នុងកន្លែងបើកបរ និងបិទថ្ងៃធ្វើដំណើរនៅបញ្ជរលក់សំបុត្រ។

មាត្រា ៤ : លិខិតអនុញ្ញាតត្រូវមានសុពលភាពសំរាប់រយៈពេលមួយឆ្នាំហើយអាចដំណើរការបន្តទៀតបាន លើកលែងតែមានយោបល់ជំទាស់ជាលាយលក្ខអក្សរពីក្រសួងទេសចរណ៍ ។

ពេលមានការផ្ទេរ ឬ លក់ អាជីវករត្រូវដាក់ពាក្យសុំទៅក្រសួងទេសចរណ៍តាមទម្រង់បែបបទដែលបានកំណត់ ។

មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតអាជីវករត្រូវដាក់ពាក្យអោយបានមុនមិនលើសពី ២ ខែ និង មិនតិចជាង ១ ខែ ។

មាត្រា ៥ : ក្នុងករណីអាជីវករបានផ្តល់ពត៌មានមិនពិត ឬប្រខិតពត៌មានពាក់ព័ន្ធក្នុងការដាក់ពាក្យសុំ ឬ មិនបានអនុវត្តតាមលក្ខខ័ណ្ឌដែលមានចែងនៅមាត្រា៣នេះ ក្រសួងទេសចរណ៍ នឹងផ្អាក ឬមិនចេញលិខិតអនុញ្ញាតជូនដោយផ្តល់ដំណឹង

ជាលាយលក្ខអក្សរដល់អាជីវករយៈពេល ៣០ថ្ងៃមុន ។

មាត្រា ៦ : ក្រសួងទេសចរណ៍នឹងចុះធ្វើអធិការកិច្ច តាមមូលដ្ឋានអាជីវកម្មទាំងអស់ក្នុងពេលវេលា ណាមួយដែលសមស្រប ។ មន្ត្រីរាជការនៃក្រសួងទេសចរណ៍ដែលចុះបំពេញការងារនេះត្រូវមានកិច្ចសហការពីមន្ត្រីរាជការ នៃក្រសួងសាធារណការ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ នគរបាល ឬ មន្ត្រីរាជការ ខេត្ត ក្រុង ។

មាត្រា ៧ : ប្រាក់បង់ប្រចាំឆ្នាំក្នុងការចេញប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម ត្រូវកំណត់ដូចខាងក្រោម នេះ ÷

ចំណុះនាវា	ប្រាក់ត្រូវបង់
អ្នកដំណើរតិចជាង ១៥ នាក់	៥០.០០០៛ ឬ US $ ២០
អ្នកដំណើរពី ១៦ នាក់	១០០.០០០៛ ឬ US $ ៤០
អ្នកដំណើរពី ៣១ នាក់ ទៅ ៦០នាក់	១៥០.០០០៛ ឬ US $ ៦០
អ្នកដំណើរ ៦១ឡើងទៅ	២៥០.០០០៛ ឬ US $ ១០០

ការផ្ទេរប័ណ្ណអនុញ្ញាតបន្តសកម្មភាពត្រូវគិត ១០ % នៃចំនួនទឹកប្រាក់ដែលបានកំណត់ខាងលើ ។

មាត្រា ៨ : ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីអាជីវករបានផ្តល់នូវសំណុំឯកសារគ្រប់គ្រាន់ ត្រឹមត្រូវ ក្នុងការដាក់ពាក្យសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម តាមការកំណត់របស់ក្រសួងទេសចរណ៍ហើយអាជីវកម្មអាចអញ្ជើញមកទទួលយកប័ណ្ណអនុញ្ញាតតាមការកំណត់ ដែលមានចុះលើបង្កាន់ដៃទទួលពាក្យ ។

មាត្រា ៩ : ក្នុងរយៈពេលបីខែ បន្ទាប់ពីមានការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍ នឹង មិនអនុញ្ញាតអោយមានការធ្វើអាជីវកម្ម ចំពោះនាវាដែលគ្មានច្បាប់អនុញ្ញាតទាន់ពេលវេលាទេ ។

មាត្រា ១០ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយ នឹងប្រកាសនេះត្រូវទុកជាមោឃៈ ។

មាត្រា ១១ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ម៉ែង សារិទ្ធ

* * *

៦ - ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសម្រេច

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សេចក្តីសម្រេចលេខ ៤៤/៩៦ ក.ធ.ស

អនុញ្ញាតជាគោលការណ៍ឱ្យបើកស្នាក់ការថ្វាយបង្គំ

នៃសាសនាគ្រិស្តរបស់សហព័ន្ធគ្រិស្តបរិស័ទខ្មែរ

« ព្រះវិហារ តាហោរ »

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញពាក្យសុំបើកស្នាក់ការថ្វាយបង្គំ នៃសាសនាគ្រិស្តរបស់សហព័ន្ធគ្រិស្តបរិស័ទខ្មែរ សំរាប់គោរពបូជាឈ្មោះ « ព្រះវិហារ តាហោរ » ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកស្នាក់ការថ្វាយបង្គំ នៃសាសនាគ្រីស្ទបរិស័ទខ្មែរសំរាប់គោរពបូជាឈ្មោះ «ព្រះវិហារតាហោរ » ដែលមានទីតាំងមួយកន្លែងស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលេខ ១៣ សង្កាត់សង្ឃរ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

ប្រការ ២ : «ព្រះវិហារ តាហោរ » ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវរាល់ខ្លឹមសារ និងឯកសារផ្សេង ៗ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : «ព្រះវិហារ តាហោរ » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការនិង សាសនាសន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្ដាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្ដីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្ដីសំរេចនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ទណ្ឌរ័ត្ន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ៤៦/៩៦ ក.ធ.ស

អនុញ្ញាតឱ្យអង្គការសុខមាលភាពព្រះពុទ្ធសាសនា

បើកការិយាល័យបណ្ដោះអាសន្នមួយនៅខ្មែរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនាដែលប្រកាសអោយប្រើតាមព្រះរាជក្រមរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ នស.រកម ០១៩៦-១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញពាក្យស្នើរបស់អង្គការសុខមាលភាពព្រះពុទ្ធសាសនា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយអង្គការ «សុខមាលភាពព្រះពុទ្ធសាសនា» បើកការិយាល័យបណ្តោះអាសន្នមួយកន្លែងនៅផ្ទះលេខ ១៣ អា ផ្លូវ ២៧៨ សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : អង្គការ «សុខមាលភាពព្រះពុទ្ធសាសនា» ត្រូវធ្វើការផ្សព្វផ្សាយខ្លឹមសារព្រះពុទ្ធសាសនាអោយបានត្រឹមត្រូវ ក្នុងគោលដៅពង្រឹង ពង្រីកវប្បធម៌ប្រពៃណី ទំនៀមទំលាប់ និង អក្សរសាស្ត្រខ្មែរ អោយកាន់តែសុក្រឹតល្អប្រសើរ ។

ប្រការ ៣ : អង្គការ «សុខមាលភាពព្រះពុទ្ធសាសនា» ត្រូវមានតំណាងម្នាក់ជាជនជាតិខ្មែរ សំរាប់ទំនាក់ទំនងការងារជាមួយក្រសួងធម្មការ និង សាសនា ។

ប្រការ ៤ : អង្គការ «សុខមាលភាពព្រះពុទ្ធសាសនា» ត្រូវគោរពអោយបានត្រឹមត្រូវតាមច្បាប់រាជរដ្ឋាភិបាលកម្ពុជា និង បទបញ្ញត្តិទាំងឡាយរបស់ក្រសួងធម្មការ និង សាសនា ។

ប្រការ ៥ : អង្គការសុខមាលភាពព្រះពុទ្ធសាសនា នាយកដ្ឋានធម្មការ , មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និង ស្ថាប័នរដ្ឋអំណាចដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយបានជោគជ័យល្អប្រសើរ ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង សណ្ណារ័ត្ន

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៣៨០ រៀល